00635351

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 14 / 01 / 2011
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

F14/4/2

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

**សំណុំរឿងលេខ៖** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

**ដាក់ទៅ៖** អង្គជំនុំជម្រះតុលាការកំពូល

**ថ្ងៃដាក់៖** ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១

**ភាគីអ្នកដាក់៖** សហមេធាវីជាតិការពារក្តីលោក **កាំង ហ្កេកអ៊ាវ** ហៅ “**ឌុច**”

**ភាសាដើម៖** **ភាសាខ្មែរ**

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ស្នើដោយភាគីអ្នកដាក់តម្កល់៖ **សាធារណៈ**

ចំណាត់ថ្នាក់សម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ៖សាធារណៈ / Public

លក្ខន្តិកៈនៃចំណាត់ថ្នាក់៖

ការពិនិត្យចំណាត់ថ្នាក់បណ្តោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿងនិងឯកសារ៖

ហត្ថលេខា៖

---

**ការឆ្លើយតបរបស់សហមេធាវីការពារក្តីជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ “ឌុច”**
**ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១០**

---

| **អ្នកដាក់ឯកសារ៖** | **អ្នកទទួលឯកសារ៖** | |
|---|---|---|
| **សហមេធាវីការពារក្តីជនជាប់ចោទ** | **អង្គជំនុំជម្រះតុលាការកំពូល** | |
| **កាំង ហ្កេកអ៊ាវ** ហៅ “**ឌុច**” | ចៅក្រម **គង់ ស្រ៊ីម** ប្រធាន | |
| មេធាវី **ការ សាវុត្ថ** | ចៅក្រម **Motoo NOGUCHI** | ចៅក្រម **ស៊ុំ រិទ្ធ** |
| មេធាវី **កង ឫទ្ធារី** | ចៅក្រម **សោម សិរីវុឌ្ឍ** | ចៅក្រម **C.N.JAYASIINGHE** |
| | ចៅក្រម **A. KLONOWIECKA-MILART** | ចៅក្រម **យ៉ា ណារិន** |

00635352

សំណុំរឿងលេខៈ ០០១/១៨-០៧-២០០៧-អ.វ.ត.ក /អ.ជ.ត.ក

F14/4/2

**<u>សហព្រះរាជអាជ្ញា</u>**

លោកស្រី **ជា លាង**

លោក **Andrew CAYLEY**

**<u>មេធាវីដើមបណ្តឹងរដ្ឋប្បវេណី</u>**

| | | |
|---|---|---|
| មេធាវី គង់ ពិសី | មេធាវី Silke STUDZINSKY | មេធាវី Annie DELAHAIE |
| មេធាវី ហុង គឹមសួន | មេធាវី Martine JACQUIN | មេធាវី Elizabeth RABESANDRATANA |
| មេធាវី យុង ផានិត | មេធាវី Philippe CANNONE | មេធាវី Karim KHAN |
| មេធាវី គីម ម៉េងឃី | មេធាវី Pierre Olivier SUR | មេធាវី Fabienne TRUSSES-NAPROUS |
| មេធាវី ម៉ុច សុវណ្ណារី | មេធាវី Alain WERNER | មេធាវី Christine MARTINEAU |
| មេធាវី ទី ស្រ៊ីនណា | មេធាវី Brianne McGONIGLE | |

# មាតិកា

ទំព័រ

I. សេចក្តីផ្តើម......................................................................................................................៤

II. ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាក្នុងឧបសគ្គករណ៍ទី១..........................១៧

III. ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាក្នុងឧបសគ្គករណ៍ទី២........................២៦

IV. សេចក្តីសន្និដ្ឋាន..............................................................................................................២៩

F14/4/2

# I. សេចក្តីផ្តើម

១. កាលពីថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១០ សហមេធាវីការពារជនជាប់ចោទបានដាក់សារណាបណ្តឹងសាទុក្ខមួយនៅតុលាការកំពូល អវតក ដើម្បីសុំឱ្យតុលាការកំពូល អវតក ចាត់ទុកសាលក្រមក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ ជាមោឃៈ និងដោះលែង **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ឱ្យមានសេរីភាពឡើងវិញ និងសុំឱ្យកំណត់ថាការឃុំខ្លួន **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ថាជាកិច្ចថែរក្សាការពារសាក្សីមានសក្តានុពល[១] សម្រាប់ចង្អុលបង្ហាញពីមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មនៅ ស-២១ ហៅគុកទួលស្លែង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ [២] ។

២. កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១០ សហមេធាវីការពារជនជាប់ចោទ ក៏បានទទួលសារណាឆ្លើយតបមកវិញពីសហព្រះរាជអាជ្ញា ដែលមានបំណងស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបដិសេធចោលបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទទាំងស្រុង[៣]។

៣. តបតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល សម្រេចផ្តល់ឱកាសឱ្យសហមេធាវីការពារជនជាប់ចោទ ដាក់ការឆ្លើយតបជាលាយល័ក្ខអក្សរទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា [៤]។

---

[១] សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០, (ឯកសារ F14 )។

[២] ចម្លើយសារភាពរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច និងកិច្ចសម្ភាសន៍របស់ Nate Thayer ជាមួយ ប៉ុល ពត , ចុះថ្ងៃទី២១ មករា ២០០៨ ,ERN 00158839, (ឯកសារ E3/11) ។

[៣] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០,( ឯកសារ F14/4 )។

[៤] សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០, (ឯកសារ F14/4/1) ។

៤. សហព្រះរាជអាជ្ញាបានទទួលស្គាល់ផងដែរនូវអត្ថន័យនៃបណ្ដឹងសាទុក្ខរបស់សហមេធាវី គឺមិនមែនរឿងពិរុទ្ធភាព ឬមិនពិរុទ្ធភាពរបស់ជនជាប់ចោទទេ គឺជារឿងយុត្តាធិការរបស់ អវតក លើបុគ្គល[៥] ។

៥. ដូចដែលបានអធិប្បាយពន្យល់ និងផ្ដល់សំអាងហេតុក្នុងសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** សហមេធាវី បានលើកយកមកបង្ហាញដល់អង្គជំនុំជម្រះតុលាការកំពូល នូវភស្តុតាងថ្មី (០១)[៦] មានសេចក្ដីសន្និដ្ឋានយ៉ាងច្បាស់នូវឋានានុក្រមរបស់ជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ទាំងនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងរដ្ឋាភិបាល គឺជាកំរិតទាបជាងគេទាំងអស់គឺជាប្រធាន សន្តិបាល ឬជាប្រធានផ្នាំគុក ។ កិច្ចការទាំងនេះត្រូវបានធ្វើឡើងដោយអ្នកជំនាញខាងប្រមូលភស្តុតាងសំរាប់សាលាក្ដី អវតក តែម្ដង គឺមជ្ឈមណ្ឌលឯកសារកម្ពុជា ។

៦. ភស្តុតាងលើសពីនេះទៅទៀត ត្រូវបានដាក់ឲ្យអង្គជំនុំជម្រះសាលាដំបូង អវតក ដោយអ្នកជំនាញការនៃការិយាល័យរបស់សហព្រះរាជអាជ្ញាគឺលោក Craig C. Etcheson អ្នកស៊ើបអង្កេតនៅការិយាល័យសហព្រះរាជអាជ្ញា[៧] ក៏បានបង្ហាញឲ្យឃើញថា **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** មានឋានានុក្រមទាបជាងគេបង្អស់គឺទាំងនៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងអាជ្ញាធររបស់កម្ពុជាប្រជាធិបតេយ្យ[៨] ។ នៅក្នុងគុកទួលស្លែង **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** មានភារកិច្ចទទួលបទបញ្ជា និងបញ្ជូនបទបញ្ជាទៅអ្នកអនុវត្តផ្ទាល់ព្រមទាំងវិភាគចម្លើយ ហើយរាយការណ៍ជូនថ្នាក់លើជាអ្នកសំរេច[៩] ។

---

[៥] ចម្លើយតបរបស់សហព្រះរាជអជ្ញាទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ២០១០, កថាខណ្ឌទី២, (ឯកសារ F14/4 )។

[៦] The selected 31 Biographies of Khmer Rough Leaders and others, Prepared for The UN Commision of Experts August-September, 1998(Duch's Biography), ERN 00626210-00626212, (ឯកសារ F14.2.4) ។

[៧] E3/32 របាយការណ៍ Craig C. Etcheson ។

[៨] ជាប្រធានកងវរៈសេនាធំ ។

[៩] ឯកសារឆ្លើយឆ្លងនៅស-២១ រវាង ឌុច ជាមួយថ្នាក់លើ, ERN 00002455 ។

៧. ភស្តុតាងទាំងអស់ដែលដាក់បញ្ចូល និងពន្យល់នៅក្នុងសារណាបណ្តឹងសាទុក្ខ[១០] សុទ្ធតែត្រូវបានចងភ្ជាប់ទៅនឹងមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អសប និង រាជរដ្ឋាភិបាលកម្ពុជា មាត្រា១ និងមាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក និងវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អវតក ស្តីពីភស្តុតាង ។

៨. នៅក្នុងសាលក្រមសំណុំរឿងលេខ០០១/១៨-០៧-២០០៧/អវតក/អជសដ មិនបានលើកមកពិភាក្សាអំពីភស្តុតាងដោះបន្ទុករបស់ជនជាប់ចោទ ថាមិនស្ថិតនៅក្នុងក្រុមមេដឹកនាំជាន់ខ្ពស់បំផុត លើឧក្រិដ្ឋកម្មនៅ ស-២១ ហៅ គុកទួលស្លែងទេ[១១] ។ ទោះបីជាសាមីខ្លួនបានចង្អុលបង្ហាញក៏ដោយ[១២]។ គឺជាការរំលោភលើច្បាប់សិទ្ធិមនុស្ស[១៣] ។

៩. នៅពេលដែល **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ចង្អុលបង្ហាញពីសមាសភាពជាមេដឹកនាំជាន់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យ និងក្រុមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះបទឧក្រិដ្ឋនៅ ស-២១ ហៅគុកទួលស្លែង ដូចជា **មាស មុត, ស៊ូ ម៉េត, សុន សេន, ប៉ង់** ក៏ចៅក្រមនៅតែធ្វើមិនដឹងមិនឮពីការចង្អុលបង្ហាញនេះ ហើយខកខានម្តងទៀតមិនបាន កោះហៅសាក្សីរូបនេះមកជជែកដេញដោលទល់មុខគ្នាជាមួយនឹងជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ឡើយ[១៤] ។

---

[១០] សារណាលើបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១០ , (ឯកសារ F14 ) ។

[១១] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ ទាំងមូល, ( ឯកសារ E188) ។

[១២] ចម្លើយសារភាពរបស់ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី០៦ ឧសភា ២០០៨ (ឯកសារ E3/41) , ERN 00186205, ERN 00186206 , ERN 00186207 "គ្រង់ចំណុចសង្កេត" ។ S-21 PRISONER LIST "1975-1978" (ឯកសារ E3/38- Annex A) ERN 00171462 មានឈ្មោះ ឈឹម សំអោក ហៅ ប៉ង់ ប្រធានសន្តិសុខ ស-៧១ , គ្រប់គ្រងអង្គភាពច្រើនទៀត ។

[១៣] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤ កថាខណ្ឌ ៣ ចំណុច ង ។

[១៤] កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៧ (ឯកសារ E3/915) ។ កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០០៨ (E3/11), ERN 00158839 ។ កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ (ឯកសារ E3/437), ERN 00159566, ERN 00159568 (ចម្លើយថាបញ្ជាចេញពីអចិន្ត្រៃយ៍, ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា )។

១០. ការជំនុំជម្រះដោយផ្តោតតែទៅលើយុត្តាធិការបទឧក្រិដ្ឋ[១៥] គឺជាការយល់ច្រឡំធ្ងន់ធ្ងររបស់ចៅក្រមលើយុត្តាធិការបុគ្គលដែលតាមមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១ និងមាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ដែលចែងយ៉ាងច្បាស់ អំពីសិទ្ធិអំណាចរបស់សាលាជម្រះក្តីទៅលើ "បុគ្គល" មានឋានានុក្រមខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងក្រុមជនទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម[១៦] ។

១១. សារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ នៅតែរក្សាជំហរត្រឹមត្រូវដដែលមិនមានការផ្លាស់ប្តូរទេស្របតាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អវតក ផ្ទុយពីការលើកឡើងទាំងស្រុងរបស់ចម្លើយតបរបស់សហព្រះរាជអាជ្ញា[១៧] ។

១២. ការប្រើប្រាស់ករណីយុត្តិសាស្ត្រដែលមិនមានការយល់ដឹងពីប្រព័ន្ធច្បាប់ Civil Law និង Common Law ក៏ជាដើមហេតុនៃការធ្វើការស្វ័យពង្រីកសិទ្ធិអំណាចរបស់ចៅក្រម ដើម្បីកាត់ក្តីតាមទំនើងចិត្ត និង

---

កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ (ឯកសារ E3/31 ), ERN 00164320 ។ កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៨ (ឯកសារ E3/31 ) ឧបសម្ព័ន្ធ I , កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ (ឯកសារ E3/489 ) ឧបសម្ព័ន្ធ ERN 00164345 , កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨ (ឯកសារE3/218) ERN 00165431, កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០៨ (ឯកសារ E3/5 ) ERN 00177626, កំណត់ហេតុយកចម្លើយ ឌុច ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០០៨ (ឯកសារ E3/12 ) ERN 00187659, ERN 00187661 ។

[១៥] ស្តាប់តែចម្លើយសាក្សីជាបុគ្គលិកគុកនៅ ស-២១, ១. ម៉ម ណៃ D22/14, D50/2, ២.ប្រាក់ ខន D19/VII, D19/ VIII, ៣.សួស ធី D22/9, ៤.មាស ប៉េងគ្រី D28/7, ៥.ហ៊ឹម ហ៊ុយ D19/VI, D51/2, ៦.គយ តេង D28/12, D50/3 ។

[១៦] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ (ឯកសារ E188) , ERN00573347,ទំព័រ១៩ វាក្យខណ្ឌ១; ERN 00573352,ទំព័រ ២៤ កថាខណ្ឌ ២៨ ។

[១៧] កថាខណ្ឌទី៤ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជបជាប់ចោទ កាំង ហ្កេកអ៊ាវហៅ ឌុច ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០, (ឯកសារ F14/4 ) ។

ប្រើប្រាស់ការរំភើបចិត្តជាងការប្រើប្រាស់ច្បាប់[១៨]។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាព្យាយាមនិយាយពង្វាងពីការរំលោភបទដ្ឋានជាសកលតាមប្រព័ន្ធច្បាប់ Civil Law ដែលកម្ពុជាប្រើប្រាស់បច្ចុប្បន្ន Nulum Crimine Sine Lege[១៩] ។ ការព្យាយាមប្រើប្រាស់ច្បាប់ Common Law ដោយលើកយកហ្លួសហេតុជាករណីយុត្តិសាស្ត្រ នៃសាលាជម្រះក្តី ICTY, ICTR[២០] មកប្រើបង្ហាញឱ្យឃើញពីការតាំងចិត្តរបស់សហព្រះរាជអាជ្ញាក្នុងការចោទប្រកាន់ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** និងយកមកផ្តន្ទាទោសអោយខាងតែបាន ទោះបីជារំលោភលើច្បាប់មានស្រាប់ និងទាំងប្រព័ន្ធច្បាប់ Civil Law **ដែលថាគ្មានច្បាប់គឺគ្មានបទល្មើសក៏ដោយ** ។ ទង្វើបែបនេះរបស់សហព្រះរាជអាជ្ញា គឺធ្វើអោយចៅក្រមដែលប្រហែលជាគ្មានទាំងពេលពិនិត្យភស្តុតាងដែលមានកំរាស់រាប់ពាន់ទំព័រ មានការជឿជាក់តាមពុំនោលអះអាងរបស់ចៅក្រមស៊ើបអង្កេត[២១] ។ វាជាដើមហេតុនៃការជំនុំជម្រះដោយច្រឡំលើរូប **កាំង ហ្កេកអ៊ាវ** ថាខ្លួនមានយុត្តាធិការបុគ្គលលើរូបបុគ្គលនេះ ។

១៣. ពេញសាលក្រម[២២] ទាំងមូលសាក្សីសុទ្ធតែត្រូវបានផ្តល់កស្សិណដោយបុគ្គលជាបុគ្គលិកគុក និង ជនរងគ្រោះក្នុងគុកទួលស្លែង ឯជនអ្នកមានឋានៈខ្ពស់ផ្សេងៗទៀត ដូចជា **នួន ជា** និងអ្នកមានឋានៈធំជាង**ឌុច** តែមានឋានៈតូចជាង **នួន ជា** ត្រូវបានគេធ្វើមិនដឹងមិនឮ មិនហៅមកសួរទល់មុខគ្នាស្របតាមច្បាប់[២៣] ។

---

[១៨] តាមគោលការណ៍ជាសកល Nulum Crimen Sine Lege នៃប្រព័ន្ធច្បាប់ Civil Law ។

[១៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ (ឯកសារ F14/4) ។

[២០] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០, ERN 00573354 ទំព័រ២៦ , ERN 00573591 ទំព័រ២៦៣, ERN 00573361 ទំព័រ៣៣, (ឯកសារ E188) ។

[២១] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០, ERN 00573351 ទំព័រ២៣ កថាខណ្ឌ ២៥, (ឯកសារ E188) ។

[២២] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០, ERN 00573365 ទំព័រ៣៧ កថាខណ្ឌ៥២ ចំណុច ១.៦.៥.៣, (ឯកសារ E188) ។

[២៣] វិធាន៨៧(១), ៨៧(២), ៨៧(៥) នៃវិធានផ្ទៃក្នុងរបស់ អវតក ។

១៤. មូលដ្ឋានសំខាន់ដែលនាំឲ្យមានការភាន់ច្រឡំយុត្តាធិការលើរូបបុគ្គល គឺដោយសារកត្តាបីយ៉ាង សូម្បីតែសហព្រះរាជអាជ្ញា ក៏មានការភាន់ច្រឡំផងដែរ ដោយចោទប្រកាន់ពីដំបូងថា **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ជាក្រុមមេដឹកនាំជាន់ខ្ពស់រហូតទាល់តែមានការស៊ើបសួរដោយសហចៅក្រមស៊ើបសួរទើបចាត់ទុកថា **កាំង ហ្កេកអ៊ាវ** មិនមែនជាក្រុមមេដឹកនាំជាន់ខ្ពស់ទេ [២៤]។

ក-រយៈពេលប្រព្រឹត្តបទល្មើសយូរពេក និងឯកសារប្រមូលបានច្រើនជាងសំណុំរឿងធម្មតា។

ខ-ការខកខានរបស់អង្គជំនុំជម្រះ មិនបានកោះហៅសាក្សីមានឋានៈខ្ពស់ជាង **ឌុច** ដូចជា **នួន ជា**, **មាស មុត**, **ស៊ូ មេត**, មកសាកសួរតទល់គ្នាតាមនីតិវិធី [២៥]។

គ-អង្គជំនុំជម្រះត្រូវបានធ្វើឲ្យរន្ធត់ចិត្តចំពោះបទឧក្រិដ្ឋសាហាវយង់ឃ្នងនៅ ស-២១ ហើយសហចៅក្រមស៊ើបសួរ មិនអាចស្វែងរកបានសាក្សីជាន់ខ្ពស់មកសាកសួរ និងទាំងភ្លេចយកសាក្សីសំខាន់មួយរូបដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅ ស-២១ គឺ **នួន ជា** ដែលត្រូវជាជនជាប់ចោទក្នុងសំណុំរឿងលេខ០០២ ក្នុងសាលាជម្រះក្តី អវតក នេះមកសាកសួរទល់មុខគ្នាជាមួយជនជាប់ចោទ។ ចំណុចនេះមានសារៈសំខាន់ណាស់ដើម្បីកំណត់យុត្តាធិការលើរូបបុគ្គល **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ថាតើគាត់ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មនៅ ស-២១ ហៅ គុកទួលស្លែង ដែរ ឬអត់[២៦]?

១៥. ការយកករណីយុត្តិសាស្ត្រដែលទទួលបានពីសាលាជម្រះក្តីអន្តរជាតិ ICTY និង ICTR ទាំងស្រុងនោះ គឺជាកំហុសឆ្គងនៃការយល់ដឹងចំពោះច្បាប់អន្តរជាតិកើតចេញពីទំនៀមទំលាប់ ។ ដោយហេតុថា ថ្វីបើច្បាប់អន្តរជាតិកើតចេញពីទំលាប់ ត្រូវបានគេអនុវត្តស្មើរតែទូទៅនៃសាលាជម្រះក្តីអន្តរជាតិ ក៏ប៉ុន្តែគេត្រូវការយល់ដឹងច្បាស់អំពីចរិតលក្ខណៈនៃបទល្មើស ស្ថានភាពក្នុងពេលប្រព្រឹត្ត និងចរិតលក្ខណៈរួមរបស់បទល្មើស និងច្បាប់ផ្តន្ទាទោស ច្បាប់ស្តីពីការកំណត់យុត្តាធិការនៃសាលាជម្រះក្តីអន្តរជាតិទាំងនោះ តើវាស៊ី

---

[២៤] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០, កថាខណ្ឌ ១៨ អនុកថាខណ្ឌ១២៩ , ERN 00573346 (ឯកសារ E188) ។

[២៥] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤ កថាខណ្ឌ ៣ ចំណុច ង ។

[២៦] វិធាន៨៧៖ វិធាននៃភស្តុតាងនៃវិធានផ្ទៃក្នុងរបស់ អវតក ត្រង់ចំណុច (១ ), (២ ) ,(៣ ) ,(៤ ) ,(៥ ) និង (៨ ) ។

00635360



F14/4/2

គ្នាទៅនឹងកង្វះខាតនៃច្បាប់ផ្តន្ទាទោស ច្បាប់ស្តីពីការកំណត់យុត្តាធិការនៃសាលាជម្រះក្តីទាំងនោះដែរឬអត់ ហើយតើសេចក្តីសម្រេចរបស់តុលាការនោះត្រូវបានគេស្វាគមន៍ដែរឬអី? បើពុំនោះទេ ករណីយុត្តិសាស្ត្រវានឹងក្លាយជាឧបករណ៍ បង្ករមហន្តរាយដល់ច្បាប់អន្តរជាតិនានា ច្បាប់ជាតិ[២៧] និងក៏អាចក្លាយជាឧបករណ៍សំរាប់សងសឹកគ្នា អំពីមនោគមន៍វិជ្ជានយោបាយ និងមិនអាចផ្តល់នូវយុត្តិធម៌ដែលតាមពិតទៅ យើងអាចរកបានដោយខ្លួនឯងនៅក្នុងច្បាប់អន្តរជាតិ និងច្បាប់ជាតិ ដោយពុំចាំបាច់ពឹងផ្អែកតែទៅលើករណីយុត្តិសាស្ត្រដែលគ្រាន់តែជាប្រភពនៃច្បាប់តែប៉ុណ្ណោះ[២៨] ។

១៦. ពាក្យថាការកំណត់និយមន័យថាជាក្រុមមេដឹកនាំជាន់ខ្ពស់ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតលើបទឧក្រិដ្ឋកម្ម គឺពុំមែនមានន័យថាគ្មានច្បាប់នោះទេ ហើយក៏មិនចាំបាច់ឱ្យគេស្វះស្វែងរកប្រភពច្បាប់អន្តរជាតិកើតដោយទំនៀមទំលាប់អន្តរជាតិតាមបែប Common Law សម្រាប់យកមកប្រើប្រឆាំងទៅនឹងច្បាប់ Civil Law ក្នុងរដ្ឋស៊ីវិល័យមួយដូចជាកម្ពុជាដែលប្រើប្រាស់ច្បាប់ Civil Law យ៉ាងជោគជាំរួចទៅហើយនោះទេ ។

១៧. ប្រសិនបើគេនៅតែជ្រើសរើសផ្លូវមួយក្នុងការដាក់ទោសឱ្យទាល់តែបានចំពោះបុគ្គលមួយរូប ដែលគេចាត់ទុកថាសង្គមស្អប់ខ្ពើម ដោយពុំគិតពីនីត្យានុកូលនៃសាលាជម្រះក្តីមួយនោះ ការកាត់ក្តីបែបនេះវានឹងក្លាយទៅជាវេទិការសងសឹកគ្នាមួយរវាងអ្នកឈ្នះ និងអ្នកចាញ់ ដូចគ្នានឹងល្បើកមួយរបស់អ្នកនិពន្ធបារាំងឡាហ្វុងតែន រឿង "ចចក និង កូនចៀម" ។ វាខុសពីគោលបំណងរបស់ អសប និងរាជរដ្ឋាភិបាលកម្ពុជា[២៩] ។

---

[២៧] ច្បាប់ស្តីពីការបង្កើត អវតក គឺទាញចេញពីក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ និងកិច្ចព្រមព្រៀងរវាង អសប និង រាជរដ្ឋាភិបាលកម្ពុជាដើម្បីបង្កើត អវតក ។

[២៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, ផ្នែក២ វិធាននៃភស្តុតាង, មាត្រា៣២១៖ ការវាយតំលៃភស្តុតាងដោយតុលាការ ។

[២៩] មាត្រា១ នៃកិច្ចព្រមព្រៀងរវាង អសប និង រាជរដ្ឋាភិបាលកម្ពុជា ដែលមានបំណងរួមគ្នាបង្កើត អវតក ដើម្បីកាត់ទោសតែទៅលើក្រុមមេដឹកនាំជាន់ខ្ពស់ និង អ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្ម ។ គោលបំណងនេះត្រូវបានប្រើដោយពាក្យប្រាប្រព្វយ៉ាង

១៨. នៅតុលាការកំពូលប្រទេស Canada[៣០] ក៏ធ្លាប់បានជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមលោកលើកទីIIដែរ ហើយតុលាការកំពូលបានផ្តល់អនុសាសន៍ដល់សាលាដំបូងនិងសាលាឧទ្ធរណ៍ Canada ដែរថា ចៅក្រម មានពេលគ្រប់គ្រាន់ក្នុងអំឡុងពេលសវនាការពីដើមដល់ចប់ ដើម្បីត្រួតពិនិត្យទាំងយុត្តាធិការលើបទល្មើស និង យុត្តាធិការលើរូបបុគ្គលដោយពុំចាំបាច់ពិនិត្យមើលម្តងមួយៗនោះទេ ។ ជាលទ្ធផល តុលាការកំពូល Canada ក៏បានរកឃើញថា គ្មានយុត្តាធិការទៅលើរូបលោក Imre Finta ហើយបានលើកលែងការចោទ ប្រកាន់។

១៩. អំណះអំណាងហួសហេតុពេកអំពីសេចក្តីសម្រេចរបស់ ICTY, ICTR និង សារ៉ាឡេអូន វាហាក់បញ្ជាក់ថា អវតក គ្មានច្បាប់ និងទាំងវិធានផ្ទៃក្នុងគ្រប់គ្រាន់ទាល់តែសោះ ហើយថារដ្ឋកម្ពុជាហាក់បីដូចជារដ្ឋឥតច្បាប់ និងកិច្ចព្រមព្រៀងរវាង អសប និង រាជរដ្ឋាភិបាលកម្ពុជា មិនអាចគ្របដណ្តប់លើ ដំណើរការកាត់ក្តីនៅ អវតក បាន[៣១] ។

២០. អំណះអំណាងរបស់សហមេធាវីការពារជនជាប់ចោទ ដែលបានលើកឡើងក្នុងសារណាបណ្តឹងសាទុក្ខ បានទាញពីភស្តុតាងក្នុងអង្គហេតុពិតប្រាកដច្បាស់លាស់ ដែលរកបានដោយការិយាល័យសហព្រះរាជអាជ្ញា និងក្រុមមេធាវីខ្លួនឯង ហើយនិងការចង្អុលបង្ហាញនូវអត្ថបទច្បាប់កំពុងមានសុពលភាពអនុវត្តស្របតាម កិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់បង្កើត អវតក វិធានផ្ទៃក្នុង អវតក ច្បាប់កម្ពុជា

---

ដូច្នេះថា៖ ដោយហេតុថានៅក្នុងសេចក្តីសំរេចចិត្តដដែលនេះ មហាសន្និបាតបានទទួលស្គាល់ការព្រួយបារម្ភពេញច្បាប់របស់ រដ្ឋាភិបាល និងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ ។

[៣០] រឿងក្តីនៅតុលាការកំពូលប្រទេស កាណាដា R v Finta, [1994] 1.S.C.R.701 Her Majesty the queen V Imire Finta ត្រូវបានចោទប្រកាន់ក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេល Nazi គ្រប់គ្រងអ៊ឺរ៉ុបក្នុងសម័យ សង្គ្រាមលោកលើកទី២ ។ Case Nos. 23023, 23097. 1993, June, 2,3; 1994, March 24 ។

[៣១] អំណះអំណាងរបស់សហព្រះរាជអាជ្ញានៅក្នុងចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, (ឯកសារ F14/4) ។

ដូចជា ក្រមនីតិវិធីព្រហ្មទណ្ឌ រដ្ឋធម្មនុញ្ញ ច្បាប់ព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលជាប្រភពនៃច្បាប់បង្កើត អវតក[៣២] ។

២១. ឯចម្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ច្រើនប្រើសំអាងច្រើនលើសលប់ ប៉ផ្ដិចប៉ផ្ដូច តាមសេចក្ដីសម្រេចរបស់សាលាជម្រះក្ដី ICTY ដែលល្បីខាងមិនគោរពសិទ្ធិមនុស្ស និងមិនមានស្តង់ដារពេញលេញដូច អវតក ទេ ។ អ្នកណាក៏បានដឹងដោយកំហឹងដែរថាសាលាជម្រះក្ដីនេះទុកជនជាប់ចោទ ស្លូម៉ូដាន មីឡូសូវិក ស្លាប់ក្នុងគុកដោយកង្វះការថែទាំសេវាសុខាភិបាល ។ ម៉្យាងវិញទៀត សាលាជម្រះក្ដីនេះមានលក្ខន្តិកៈមិនដាក់កំរិតលើយុត្តាធិការបុគ្គលដូច អវតក ទេ[៣៣] ។ ហេតុដូច្នេះការយកគំរូតាម ICTY គឺជាកង្វះខាតសតិសម្បជញ្ញៈច្បាប់ និងគ្មានមនសិកាគោរពសិទ្ធិមនុស្សក្នុងការស្វែងរកយុត្តិធម៌ពិតប្រាកដ [៣៤]។

២២. នៅទីនេះ យើងនៅតែសង្ឃឹមថាគ្មាននរណាម្នាក់នឹងយកគំរូរបៀបកាត់ក្ដីនៅសាលាជម្រះក្ដីក្នុងប្រទេសអ៊ីរ៉ាក់ មកធ្វើជាអំណះអំណាងគាំទ្រទឡ្ហីករណ៍របស់ខ្លួនទេ ។ សាលាជម្រះក្ដីខ្លះមិនឆ្លុះបញ្ចាំងឲ្យការគោរពការអនុវត្តន៍ស្តង់ដារអន្តរជាតិឡើយ[៣៥] ។

២៣. មូលហេតុដែលសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** មិនមានយោងប្រតិចារឹកនៅក្នុងសាលក្រម ក៏ព្រោះតែសាលក្រមគ្មានប្រតិចារឹកអំពីសាក្សីដែលមានឋានៈខ្ពស់ជាង **ឌុច** ដូចជា **នួន ជា, ស៊ូ មេត, មាស មុត** ដែលមិនត្រូវបានគេហៅមកសួរទល់មុខជនជាប់ចោទ [៣៦] ។ តែបែរជាមានក្នុងសំណុំរឿងលេខ០០២ ទៅវិញ ។

---

[៣២] សារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី១៨ វិច្ឆិកា ឆ្នាំ២០១០, (ឯកសារ F14) ។

[៣៣] មាត្រា៦, មាត្រា៧, មាត្រា៩ នៃលក្ខន្តិកៈសាលាជម្រះក្ដី ICTY ។

[៣៤] ជនជាប់ចោទ ស្លូម៉ូដាន មីឡូសូវិក នៃសាលាក្ដី ICTY បានស្លាប់ក្នុងគុក មុនពេលកាត់ក្ដីចប់ ។

[៣៥] កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៤ កថាខណ្ឌ ៣ ចំណុច ង ។

[៣៦] វិធាន៨៧ (១), ៨៧(២) នៃវិធានផ្ទៃក្នុង អវតក ។

00635363



F14/4/2

២៤. សហមេធាវីការពារជនជាប់ចោទ នៅតែប្រកាន់ជំហរថាខ្លួននៅឈរចំចំណុចកណ្តាលនៃរង្វង់ច្បាប់ Civil Law យ៉ាងខ្ជាប់ខ្ជួន ហើយនឹងព្យាយាមកាត់បន្ថយការជជែកប៉ផ្ទិចប៉ផ្ទួចអំពីសេចក្តីសម្រេចចិត្តខុស ឬត្រូវនៃសាលាជំម្រះក្តីផ្សេងៗច្រើនពេកទេ ។ យើងព្យាយាមប្រើប្រភពច្បាប់អន្តរជាតិយកមកសំអាងបន្ថែមតាមកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា[៣៧] តែល្គឹកណា៖

-កង្វះចន្លោះច្បាប់បង្កើត អវតក, កិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា, ច្បាប់ព្រហ្មទណ្ឌកម្ពុជា, រដ្ឋធម្មនុញ្ញកម្ពុជា វិធានផ្ទៃក្នុង អវតក, សន្ធិសញ្ញា និងអនុសញ្ញាផ្សេងៗ ។

-ប្រភពនៃច្បាប់អន្តរជាតិផ្សេងទៀត ដែលយកមកប្រើត្រូវតែស្របតាមប្រពន្ធ័ច្បាប់ Civil Law, កិច្ចព្រមព្រៀងរវាងអសប និងរាជរដ្ឋាភិបាលកម្ពុជា,ច្បាប់បង្កើត អវតក និងច្បាប់ព្រហ្មទណ្ឌកម្ពុជា ។

-ប្រភពនៃច្បាប់នោះមិនធ្វើអោយមានមហន្តរាយដល់រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៥១ថ្មី ស្តីពីការបែងចែកអំណាច ។ តាមមាត្រានេះអង្គជំនុំជម្រះមិនអាចបង្កើតច្បាប់ដោយខ្លួនឯងទេ ។ ការហាមប្រាមប្រើករណីយុត្តិសាស្ត្រត្រូវកំណត់ក្នុងមាត្រា៥១ថ្មី ត្រង់ចំណុចស្តីពីការបែងចែកអំណាច ។ ព្រះរាជអាជ្ញាបានលើកឡើងថា សហមេធាវីការពារជនជាប់ចោទបានលើកម្តងហើយម្តងទៀតដដែលៗ អំពីការខកខានរបស់អង្គជំនុំជម្រះសាលាដំបូងដែលមិនបានពិចារណាទៅលើសេចក្តី "សន្និដ្ឋាន" របស់ខ្លួន អំពីយុត្តាធិការបុគ្គល[៣៨] ។

២៥. ការលើកឡើងនេះសំដៅលើសាលក្រម ត្រង់សេចក្តីផ្តើមដែលចៅក្រមលើកឡើងថា នៅក្នុងអំឡុងពេលសវនាការ[៣៩] ។ ការលើកឡើងបែបនេះផ្ទុយនឹងវិធានផ្ទៃក្នុងរបស់ អវតក[៤០] ផ្ទុយនឹងនីតិវិធីព្រហ្មទណ្ឌកម្ពុជា[៤១]។

---

[៣៧] មាត្រា១២(១) អំពីនីតិវិធី ។ មាត្រា១២(១)នៃកិច្ចព្រមព្រៀងរវាង អសប និង រាជរដ្ឋាភិបាលកម្ពុជា តម្រូវឲ្យនីតិវិធីស្របតាមច្បាប់កម្ពុជា ។

[៣៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, ត្រង់កថាខណ្ឌ៨ ទំព័រ១១ , (ឯកសារ F14/4 )។

[៣៩] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០, (ឯកសារ E188 ) ។

F14/4/2

២៦. ឆ្លើយតបទៅនឹងកថាខណ្ឌ៨ ចំណុច៣ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ **កាំង ហ្គេកអ៊ាវ ហៅ ឌុច** ។ វាជាការពិតដែលមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា និយាយសំដៅដល់គោលបំណងដែលយកទៅកាត់ទោសតែ **ចំពោះក្រុមមេដឹកនាំជាន់ខ្ពស់ និងក្រុមអ្នកទទួលខុសត្រូវខ្ពស់បំផុត**[៤២] ។

២៧. ពាក្យថាខ្ពស់បំផុតគួរត្រូវបកស្រាយតាមចំណេះដឹង និងឆន្ទានុសិទ្ធិរបស់ចៅក្រម[៤៣] ស្របតាមច្បាប់ ដោយទាញចេញនូវសំអាងហេតុជាភស្តុតាងបានមកពីអង្គហេតុពិត និងបង្ហាញពីអត្ថបទច្បាប់ណាមួយ[៤៤]។

២៨. យុត្តិសាស្ត្ររបស់តុលាការអន្តរជាតិផ្សេងៗទៀតគឺ ICTY បានបកស្រាយអំពីអត្ថន័យនៃឃ្លា "មេដឹកនាំជាន់ខ្ពស់បំផុត" ថាសំដៅដល់បុគ្គលទាំងឡាយណាដែលមានមុខតំណែង និង មុខងាររបស់ពួកគេក្នុងឋានានុក្រមរដ្ឋបាល ពោលគឺទាំងតាមផ្លូវច្បាប់ (de jure) និង តាមព្រឹត្តហេតុជាក់ស្តែង (de facto) ត្រូវបានចោទថាស្ថិតក្នុងកម្រិតអំណាចដែលសមស្របចាត់ទុកពួកគេថាស្ថិតក្នុងចំណោម "អ្នកដឹកនាំថ្នាក់ខ្ពស់បំផុត" គឺមិនមែន "ថ្នាក់កណ្តាល" ទេ[៤៥]។ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្តីរបស់ ICTY បានពិចារណាលក្ខណៈវិនិច្ឆ័យ ដូចជា <u>តួនាទីថ្នាក់ដឹកនាំអចិន្ត្រៃយ៍</u> និង <u>ក្នុងរយៈពេលកំណត់កម្រិតថ្នាក់ដឹកនាំជាន់ខ្ពស់</u>(បើមាន) <u>តំណែងទទួលខុសត្រូវថ្នាក់នយោបាយណាមួយរបស់ជនជាប់ចោទ</u> (ឧទាហរណ៍

---

[៤០] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុងរបស់ អវតក ។

[៤១] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផ្នែក២ ស្តីពីវិធានភស្តុតាង មាត្រា៣២១ ។

[៤២] ពាក្យប្រារព្ធនៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា និងគោលបំណងនៃកិច្ចព្រមព្រៀងនេះត្រង់ប្រការ១ ។

[៤៣] ក្រមនីតិវិធីព្រហ្មទណ្ឌផ្នែក២ ជំពូក៣ វិធាននៃភស្តុតាង មាត្រា៣២១ ។

[៤៤] ច្បាប់រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា៥១(ថ្មី) ស្តីពីការបែងចែកអំណាច ។ អង្គជំនុំជម្រះគ្មានសិទ្ធិបង្កើតច្បាប់ដោយខ្លួនឯងទេ វាជាសិទ្ធិផ្តាច់មុខរបស់អង្គនីតិបញ្ញត្តិ។

[៤៥] *Prosecutor v Dragomir Milosovic*, Decision on Referral of Case Pursuant to Rule 11 *bis*, Referral Bench, 8 July 2005, para 22. http://www.icty.org/x/cases/dragomir_milosevic/tdec/en/050708.htm.

តាមរយៈការចចារជាមួយសមាសភាពអន្តរជាតិ) និង ចំនួនបុគ្គលដែលស្ថិតក្រោមការបញ្ជារបស់ជនជាប់ចោទ។ បើផ្ទៀងផ្ទាត់លក្ខខណ្ឌខាងលើនេះ ទៅនឹងរូបបុគ្គល **ឌុច** ឃើញថាពុំដូចគ្នាទេ ព្រោះថា **ឌុច** ពុំត្រូវបានចោទជាមេដឹកនាំខ្ពស់បំផុតទេ ហើយក៏ពុំមានលក្ខខណ្ឌអ្វីតម្រូវឱ្យ **ឌុច** ទៅជា"ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដែរ។ ដោយហេតុថា:

១- **ឌុច** ជាលេខាមន្ទីរស-២១ បើគិតពីឋានានុក្រមរដ្ឋបាលក្នុងច្បាប់ជាតិ គឺស្មើនឹងថ្នាក់ការិយាល័យ ឬថ្នាក់អនុនាយកដ្ឋាន[៤៦]។

២- **ឌុច** ពុំមានតំណែងទទួលខុសត្រូវថ្នាក់នយោបាយណាមួយក្នុងអចិន្ត្រៃយ៍បក្សទេ[៤៧]។

៣- **ឌុច** មានតួនាទីជាអ្នកពាំនាំបញ្ជាពីថ្នាក់លើទៅថ្នាក់ក្រោម "រាល់ការបញ្ជាទាំងអស់ពុំឆ្លុះបញ្ចាំង ឬចេញពីអំណាចឆន្ទៈផ្ទាល់របស់គាត់ទេ"[៤៨]។

៤- **ឌុច** ពុំមានបុគ្គលិកដែលឋិតក្រោមបញ្ជា(ពីឆន្ទៈ)ផ្ទាល់របស់គាត់ទេ ព្រោះមន្ទីរស-២១ បានប្រតិបត្តិការតាមការណែនាំ និងក្រោមបញ្ជាផ្ទាល់របស់អាជ្ញាធរខ្ពស់បំផុតនៃបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ[៤៩]។

ដូច្នេះ ការព្យាយាមទាញ **ឌុច** ឱ្យទៅជា "ជនដែលទទួលខុសត្រូវខ្ពស់បំផុត" ដោយផ្អែកតាមយុត្តិសាស្ត្ររបស់តុលាការអន្តរជាតិ ICTY វាពុំត្រឹមត្រូវទេ ហើយថែមទាំងនាំឱ្យបាត់បង់តម្លៃច្បាប់ជាតិដែលមានស្រាប់ទៀតផង។

២៩. សហព្រះរាជអាជ្ញាគួរតែព្យាយាមសិក្សាឱ្យបានច្បាស់រវាងពាក្យ**"ជនទទួលខុសត្រូវទាប"** និង **"ជនសង្ស័យ"** ការលើកឡើងនៅក្នុងចម្លើយតបរបស់ខ្លួន[៥០] ថា:"ខ្លឹមសារក្នុងកថាខណ្ឌ ៣៧ នៃសារណារបស់សហមេធាវី

[៤៦] ប្រកាសរបស់ក្រសួងមហាផ្ទៃ ស្តីពីការគ្រប់គ្រងពន្ធនាគារ ចុះថ្ងៃទី ៣១ ខែ មិនា ឆ្នាំ១៩៩៨ ។

[៤៧] សេចក្តីសម្រេចរបស់គណៈមជ្ឈិមចុះថ្ងៃទី៣០ មីនា ឆ្នាំ១៩៧៦ អំពីបញ្ហាផ្សេងៗមួយចំនួន, ERN 00003136-00003142 ។

[៤៨] កថាខណ្ឌ ២៥៦ សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងនៃ អ.វ.ត.ក ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ (ឯកសារ E188 ) ។

[៤៩] ឯកសារ D3, ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា, កថាខណ្ឌ ៤៩ ។

[៥០] ឯកសារ F14/4 , កថាខណ្ឌ ២៩ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០ ។

ការពារជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ជាការយល់ខុស ហើយផ្ទុយទៅនឹងមាត្រា ២៩ ថ្មី នៃច្បាប់ អ.វ.ត.ក" គឺក្នុងទស្សនៈទុទ្ធិដ្ឋិនិយម មានចេតនាទុច្ចរិត ដើម្បីបន្ទាបតម្លៃពិតប្រាកដនៃសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារក្ដីជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ។

ការពិតក្នុងខ្លឹមសារនៃកថាខណ្ឌ ៣៧ សារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារក្ដីជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** នោះបានសរសេរថា:

*"ច្បាប់ អ.វ.ត.ក ដែលមានមូលដ្ឋានចេញពីក្រមព្រហ្មទណ្ឌ ឆ្នាំ១៩៥៦ ក៏ដូចគ្នាដែរគឺ មិនអនុញ្ញាតឱ្យផ្ដន្ទាទោស ជនដែលទទួលខុសត្រូវ**ទាប** ចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ ព្រោះដោយយល់ថា ជនទាំងនោះអនុវត្តតាមបញ្ជារបស់ថ្នាក់លើ។"*

ការអះអាងខាងលើនេះ គឺសំដៅទៅលើ "ជនដែលទទួលខុសត្រូវ**ទាប**" ហើយបានអនុវត្តតាមបញ្ជារបស់ថ្នាក់លើ ដូចគ្នានឹងចារីដទៃទៀត។

ចំណែកឯខ្លឹមសារនៅក្នុងមាត្រា ២៩(៤) ថ្មី នៃច្បាប់ អ.វ.ត.ក បានចែងសំដៅទៅលើ "មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង អ្នកទទួលខុសត្រូវ**ខ្ពស់**បំផុត" គឺមានន័យដូចខាងក្រោម:

*"ប្រការដែលថា ជនសង្ស័យ[៥១] បានប្រព្រឹត្តអំពើឧក្រិដ្ឋ ទៅតាមបញ្ជារបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ឬរបស់ថ្នាក់លើណាមួយ មិនអាចជួយជនសង្ស័យនេះ ឱ្យរួចផុតពីការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះបានឡើយ"* ។

៣០. ពាក្យថាទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មគឺសំដៅទៅលើចារី ឬសហចារី ដែលជាអ្នកបង្កើតបទឧក្រិដ្ឋកម្មឡើងមកនិងដាក់ឱ្យវាដំណើរការបានសម្រេចផល ឬអាចបញ្ឈប់វាបាន[៥២]។ ឯចារី ឬ សហចារី

---

[៥១] សូមអាន មាត្រា២ ថ្មី ក្នុងកថាខណ្ឌ២ នៃច្បាប់ អ.វ.ត.ក។

[៥២] -សេចក្ដីសម្រេចរបស់គណៈមជ្ឈិមថ្ងៃទី៣០ ខែមិនា ឆ្នាំ១៩៧៦ ស្ដីពីការកំទេចជុំវិញមជ្ឈិម និងតាមភូមិភាគ, ERN00003136-ERN00003142។

F14/4/2

ដែលធ្វើតាមបញ្ជាគេមិនស្ថិតក្នុងរង្វង់នៃមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា ហើយក៏ដូចគ្នានឹងមាត្រា១, មាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ទេ ។

៣១. ក្នុងសាលក្រម[៥៣] បានបញ្ជាក់ថា ជនជាប់ចោទបានបំពេញតួនាទីរបស់ខ្លួនតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ហើយបានដឹកនាំបញ្ជាទៅបុគ្គលិករបស់ខ្លួនបន្តទៀត។ ដោយពិចារណាអំពីតួនាទីរបស់បុគ្គលិកទាំងអស់នោះ នៅក្នុងរដ្ឋមួយដែលមានការគ្រប់គ្រង អង្គជំនុំជម្រះបានសន្និដ្ឋានថា អ្នកសួរចម្លើយនៅមន្ទីរស-២១ និងមន្ទីរស-២៤ ដែលបានប្រព្រឹត្តអំពើទារុណកម្មទាំងឡាយ បានអនុវត្តសមត្ថកិច្ចជាផ្លូវការរបស់ខ្លួន ហើយត្រូវបានចាត់ទុក ជាសមត្ថកិច្ចផ្លូវការរបស់ចារី។

## II. ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាក្នុងឧទ្ធរណ៍ទី១ [៥៤]

៣២. សហព្រះរាជអាជ្ញាឆ្លើយតបដោយឥតសំអាងហេតុ និងដោយមិនបានបង្ហាញពីអត្ថបទច្បាប់ ៖

-ភស្តុតាងបានមកពីការិយាល័យសហព្រះរាជអាជ្ញាខ្លួនឯង បានដាក់ចូលក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសជ ។

---

-គណៈអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា បានត្រួតត្រា និងចាត់តាំងមន្ត្រីជាន់ខ្ពស់ទាំងអស់ឲ្យកាន់តំណែងរដ្ឋាភិបាល និងយោធា។ តាមរបាយការណ៍របស់អ្នកជំនាញនៃការិយាល័យសហព្រះរាជអាជ្ញាលោក Craig C.Etcheson, ERN 00314784 ទំព័រ៧ (ឯកសារ E3/32) ។

-ការប្រជុំអចិន្ត្រៃយ៍ ថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥, ERN 00019108-0019126 ។

-ច្បាប់ស្តីពីការបង្កើត អវតក មាត្រា១ មាត្រា២(ថ្មី) ដែលកំណត់សិទ្ធិអំណាចរបស់ អវតក តែទៅលើក្រុមមេដឹកនាំខ្ពស់បំផុត និងអ្នកទទួលខុសត្រូវខ្ពស់បំផុតលើឧក្រិដ្ឋកម្មដែលកើតមានឡើងក្នុងប្រទេសកម្ពុជាក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

[៥៣] សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង អ.វ.ត.ក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ (ឯកសារ E188 ), កថាខណ្ឌ ២៥៦។

[៥៤] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, ត្រង់ចំណុច២ កថាខណ្ឌ១១, (ឯកសារ F14/4 )។

-ភស្តុតាងបានមកពីការជជែកដេញដោលនៅក្នុងពេលសវនាការ ដែលបង្ហាញថា **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** មានការទទួលខុសត្រូវលើឧក្រិដ្ឋកម្មនៅ ស-២១ ហៅគុកទួលស្លែង ។

៣៣. ការអះអាងថា ចម្លើយតបរបស់សហព្រះរាជអាជ្ញា[៥៥] សាលាដំបូងមិនបានភាន់ច្រឡំលើយុត្តាធិការបុគ្គលលើរូប **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** មិនបានពឹងផ្អែកលើភស្តុតាង[៥៦] ដែលចងភ្ជាប់ដោយអត្ថបទច្បាប់ណាមួយឡើយ គឺពោលឲ្យតែរួចពីមាត់ គឺសុំបដិសេធចោល ។

៣៤. បើសិនជាយើងប្រើប្រាស់ឯកសារជាការសន្និដ្ឋាន លើភស្តុតាងប្រមូលបានដោយការិយាល័យសហព្រះរាជអាជ្ញា ដែលមានអ្នកឯកទេស Craig C. Etcheson[៥៧] និងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[៥៨] យើងនឹងមើលឃើញភ្លាមថា៖

-គុកទួលស្លែងជាគុកសំងាត់យោធា ។

-ឌុចមានឋានៈត្រឹមតែជាប្រធានវរៈសេនាធំ[៥៩] ។

-គុកទួលស្លែងស្ថិតនៅក្រោមបញ្ជារបស់យោធាមជ្ឈិម និងអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា[៦០]។

-កាំង ហ្គេកអ៊ាវ ហៅ ឌុច មានឋានៈត្រឹមតែជាលេខាស-២១ ហៅ គុកទួលស្លែង ឬលេខាកងវរៈសេនាធំយោធាតែប៉ុណ្ណោះ[៦១] ។

---

[៥៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, (ឯកសារ F14/4 )។

[៥៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, ត្រង់ចំណុច២ កថាខណ្ឌ១១ ចំណុច (១) ចំណុច(២), (ឯកសារ F14/4 )។

[៥៧] E3/32 របាយការណ៍ Craig C. Etcheson ។

[៥៨] The selected 31 Biographies of Khmer Rough Leaders and others, Prepared for The UN Commision of Experts August-September, 1998 (Duch's Biography) , ERN 00626210-00626212, (ឯកសារ F14.2.4 )។

[៥៩] របាយការណ៍របស់អ្នកជំនាញការ Craig C. Etcheson កថាខណ្ឌ ១១៥, ERN 00314824, (ឯកសារ E3/32 )។

[៦០] E3/32 របាយការណ៍ Craig C. Etcheson កថាខណ្ឌ២៤ អំពីសន្តិសុខ, (ឯកសារ E3/32 ), ERN 00314787, 00314834។

-កាំង ហ្គេកអ៊ាវ ហៅ ឌុច មានភារកិច្ចទទួលបញ្ជាថ្នាក់លើ រួចបញ្ជូនបញ្ជាទៅអនុវត្តរួចរាយការណ៍ទៅថ្នាក់លើវិញ[៦២]។

-កាំង ហ្គេកអ៊ាវ ហៅ ឌុច មានឋានៈទាបជាងគេនៅមន្ទីរសេនាធិការកងទ័ពមជ្ឈិម[៦៣]។

-កាំង ហ្គេកអ៊ាវ ហៅ ឌុច នៅក្រោមបញ្ជា ស-៧១ មាន ប៉ង់ និង លឺន ជាអ្នកដឹកនាំក្រោមបញ្ជាផ្ទាល់របស់ ប៉ុល ពត[៦៤]។

៣៥. ភស្តុតាងទាំងនេះដែលបង្ហាញថា **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** មិនស្ថិតនៅក្រោមមាត្រា១ មាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក[៦៥] ទេ ។ ហេតុដូច្នេះ សូមឱ្យតុលាការកំពូល អវតក លើកមកពិនិត្យសារឡើងវិញអំពីភស្តុតាងដែលមិនភ្ជាប់ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ទៅនឹង មាត្រា១ មាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ។

៣៦. ឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ត្រង់កថាខណ្ឌ១២ ដែលថា "ការជំទាស់របស់ដើមបណ្តឹងសាទុក្ខអំពីយុត្តាធិការមកលើរូបគាត់ ដែលត្រូវបង្ហាញនៅចុងក្រោយនៃសវនាការដែលមានរយៈពេលប្រាំបួនខែ" យឺតពេលហើយដោយអនុលោមតាមវិធាន៨៩ ។ ផ្ទុយទៅវិញតាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អវតក បានអនុញ្ញាតឱ្យបង្ហាញភស្តុតាងគ្រប់ពេលទាំងអស់នៅក្នុងអំឡុងពេលសវនាការ ។ ឯសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារជនជាប់ចោទ ពឹងផ្អែកលើភស្តុតាង៖

---

[៦១] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០, (ឯកសារ E188 ), កថាខណ្ឌ១២៩ ។ របាយការណ៍របស់អ្នកជំនាញការ Craig C. Etcheson កថាខណ្ឌ ១១៥, (ឯកសារ E3/32 )។

[៦២] សូមអានឯកសារសរសេរដៃរបស់ សុន សេន ផ្ញើមកឱ្យ កាំង ហ្គេកអ៊ាវ ហៅ ឌុច , ERN 00002455,D91/I ។

[៦៣] របាយការណ៍របស់អ្នកជំនាញការ Craig C. Etcheson , កថាខណ្ឌ១១៧, ERN 00314825, (ឯកសារ E3/32 )។

[៦៤] របាយការណ៍របស់អ្នកជំនាញការ Craig C. Etcheson, កថាខណ្ឌ១៣៣, ERN 00314833-00314834 , (ឯកសារ E3/32 )។

[៦៥] អវតក មានយុត្តាធិការតែទៅលើក្រុមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និង ក្រុមអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម ។

១-ឯកសារដែលមាននៅក្នុងសំណុំរឿងទាំងអស់ ហើយដែលត្រូវបានលើកយកមកធ្វើការបញ្ជាក់អំណះអំណាងលើជនជាប់ចោទ ។

២-សាក្សីធ្វើសក្ខីកម្មនៅចំពោះមុខតុលាការ ។

៣-អំណះអំណាងរបស់អ្នកជំនាញការ ។

ទើបអាចធ្វើសេចក្តីសន្និដ្ឋានបាន ហើយសេចក្តីសន្និដ្ឋានដោយពឹងផ្អែកលើភស្តុតាងបែបនេះ ចៅក្រមត្រូវតែធ្វើការផ្ទៀងផ្ទាត់ រាល់អំណះអំណាងរបស់សហមេធាវីការពារជនជាប់ចោទជាមួយនឹងភស្តុតាងផ្ទុយគ្នា ប្រសិនបើជាគេអាចរកបាន។ ចៅក្រមត្រូតពិនិត្យមើលភស្តុតាងទាំងពីរព្រមគ្នាបាន មិនមែនមិនអាចត្រួតពិនិត្យភស្តុតាងលើយុត្តាធិការខ្លួនឯង ដោយហេតុថាលើកឡើងនៅគ្រាចុងក្រោយនៃអង្គសវនាការរយៈពេលប្រាំបួនខែនោះទេ ។ ភស្តុតាងអំពីយុត្តាធិការ មានសារៈប្រយោជន៍ខ្លាំងណាស់ ហើយត្រូវបានគេលើកឡើងបានគ្រប់ពេលវេលាតាមវិធាន៨៧ នៃវិធានផ្ទៃក្នុង [៦៦]។

៣៧. ឆ្លើយតបទៅនឹងកថាខណ្ឌ១៥ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ ។ ព្រះរាជអាជ្ញាមានការភាន់ច្រឡំទៅលើវិធាន៨៩ ដោយកំណត់រាល់ភស្តុតាងទាំងអស់ដែលលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានដោយពឹងផ្អែកលើវិធាន៨៩ ជាជាងការពិនិត្យ

---

[៦៦] តុលាការកំពូលប្រទេសកាណាបានលើកឡើងថាលក្ខខណ្ឌយុត្តាធិការមិនចាំបាច់បង្ហាញថាហួសពីវិមតិសង្ស័យទេ ។ ប៉ុន្តែចៅក្រមជំនុំជម្រះត្រូវតែពិចារណាពីភស្តុតាងដើម្បីបំពេញតាមយុត្តាធិការ ហើយចៅក្រមជំនុំជម្រះមិនគ្រាន់តែផ្អែកតែទៅលើការវាយតម្លៃរបស់ខ្លួនចំពោះលក្ខខណ្ឌទាំងនេះតែទៅលើបទចោទ ដែលគេបានធ្វើឡើងនោះឡើយ ។ ដោយសារតែអង្គហេតុមួយចំនួនដែលចាំបាច់ក្នុងការបង្កើតយុត្តាធិការមិនដូចគ្នា នឹងអង្គហេតុដែលចាំបាច់សម្រាប់គណៈវិនិច្ឆ័យសម្រាប់ការសម្រេចរបស់គណៈវិនិច្ឆ័យលើបទល្មើសដែលកំពុងកើតឡើងនោះ រាល់សេចក្តីសម្រេចមិនអាចធ្វើឡើងដោយគណៈវិនិច្ឆ័យបានទេ ។ ដូចដែលចៅក្រមជំនុំជម្រះពិនិត្យមើលភស្តុតាងទាក់ទងទៅនឹងបញ្ហាយុត្តាធិការដែរនោះជាទូទៅ វានឹងមានប្រសិទ្ធិភាពជាង ប្រសិនបើឲ្យចៅក្រមជំនុំជម្រះគិតពិចារណាពីបញ្ហាយុត្តាធិការស្របគ្នានឹងពេលដែលគណៈវិនិច្ឆ័យពិនិត្យមើលភស្តុតាងដែលទាក់ទងនឹងបទល្មើសដែរ ។ ទាំងអស់នេះជាការបង្ហាញឲ្យឃើញថា ភស្តុតាងដែលចង្អុលបង្ហាញយុត្តាធិការរបស់សាលាជម្រះក្តីនៅតែមានសារប្រយោជន៍ និងត្រូវបានគេលើកយកមកបង្ហាញនិងទាញជាអំណះអំណាងបានគ្រប់ពេលវេលាដោយពឹងផ្អែកទៅលើសក្ខីកម្មផ្តល់ដោយអ្នកជំនាញការ ឬសាក្សីដ៏មានសក្តានុពលនានា ។ ការទាត់ចោលភស្តុតាងចង្អុលបង្ហាញពីបញ្ហាយុត្តាធិការសាលាជម្រះក្តី ដោយការលើកឡើងថាមិនបានឡើកឡើងទាន់ពេលវេលាមិនអាចទទួលយកបានតាមបណ្តាប្រព័ន្ធតុលាការនៅអរិយប្រទេសមួយចំនួន ។

តាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អវតក[៦៧] ។ ការវិនិច្ឆ័យសេចក្តីដោយមិនពឹងផ្អែកភស្តុតាងគ្រប់ជ្រុងជ្រោយពេលសវនាការ ឬការទាត់ចោលភស្តុតាងណាមួយឥតសំអាងហេតុ មិនមែនជាសេចក្តីវិនិច្ឆ័យសុចរិតទេ ។ ចៅក្រមនៅតែមានពេលវេលាគ្រប់គ្រាន់សំរាប់ត្រួតពិនិត្យថ្លឹងថ្លែងអំពីភស្តុតាង ទាំងបទល្មើស និងទាំងយុត្តាធិការបុគ្គល[៦៨] ។ នៅពេលចៅក្រមបានពិនិត្យភស្តុតាងគ្រប់ទាំងអស់ ទាំងដោះបន្ទុក និងដាក់បន្ទុកនោះស្របតាមវិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អវតក ហើយវិធាន៨៩ នៃវិធានផ្ទៃក្នុង មិនអាចមករារាំងកិច្ចការតុលាការក្នុងការផ្តល់យុត្តិធម៌ដល់ជនជាប់ចោទនោះទេ ។ ការលើកឡើងថា សេចក្តីសន្និដ្ឋានចុងក្រោយបង្អស់របស់សហមេធាវីការពារជនជាប់ចោទនៅពេលចុងក្រោយបង្អស់នៃ-សវនាការថា "ជាអញ្ញត្រកម្មលើកឡើងយឺតពេល" គឺផ្ទុយនឹងទំលាប់អនុវត្តផ្អែកតាមនីតិវិធីនៃតុលាការកម្ពុជា[៦៩]។

៣៨. ឆ្លើយតបទៅនឹងកថាខណ្ឌ១៥ កថាខណ្ឌ១៦ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ។ បញ្ហាយុត្តាធិការវាមិនមែនជាអញ្ញត្រកម្មទេ នៅក្នុងសាលក្រមសំណុំរឿងលេខ០០១/១៨-០៧-២០០៧/អវតក/អជសជ[៧០] ក៏បានលើកឡើងវិញរំលឹកពីយុត្តាធិការលើជនជាប់ចោទដែរ។ យោងតាមវិធាននៃភស្តុតាងដែលអនុញ្ញាតឲ្យរំលឹកឡើងគ្រប់ពេលវេលានៃរយៈពេលសវនាការនោះ ទោះបីជាពីមុនមកភស្តុតាងអំពីយុត្តាធិការ មិនទាន់លេចខ្លួនឡើងហើយសហមេធាវីក៏គ្មានអ្វីធ្វើសំអាង នៅក៏មិនជាអ្វីដែរ ព្រោះថាសេចក្តីសន្និដ្ឋានរបស់សហមេធាវីចុង

[៦៧] វិធាន៨៧ នៃវិធានផ្ទៃក្នុងរបស់ អវតក ស្តីពីភស្តុតាង ។

[៦៨] អនុសាសន៍របស់តុលាការកំពូលប្រទេសកាណាដា ក្នុងសំណុំរឿង R v Finta, [1994] 1.S.C.R.701 Her Majesty the queen V Imire Finta ត្រូវបានចោទប្រកាន់ក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេល Nazi គ្រប់គ្រងអ៊ឺរ៉ុបក្នុងសម័យសង្គ្រាមលោកលើកទី២ ។ Case Nos. 23023, 23097. 1993, June, 2,3; 1994, March 24 ។

[៦៩] តុលាការកម្ពុជាអនុវត្តជាទូទៅ មេធាវីត្រូវលើកសេចក្តីសន្និដ្ឋានចុងក្រោយបង្អស់សំរាប់ឲ្យចៅក្រមពិចារណាសេចក្តី ។

[៧០] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០ (ឯកសារ E188 ) កថាខណ្ឌ១២ (១.៤) ។

ក្រោយគឺពឹងផ្អែកលើភស្តុតាងដែលពន្លេចខ្លួនមកក្នុងអង្គសវនាការទាំងមូល លើភស្តុតាងអំពីយុត្តាធិការលើបុគ្គល [៧១]។

៣៩. ការលើកឡើងពីយុត្តាធិការ ជាទូទៅក្នុងសាលាក្តីមានសមាសធាតុចំនួនបួន គឺយុត្តាធិការបុគ្គល (Ratione personae) យុត្តាធិការដែនដី (Ratione Loci) យុត្តាធិការពេលវេលា (RationeTemoris) និងយុត្តាធិការសម្ភារៈ(Ratione Materiae)[៧២]។ ការកំណត់ដែនវិសាលភាពយុត្តាធិការរបស់សាលាជម្រះក្តីព្រហ្មទណ្ឌមានសារៈសំខាន់ណាស់ ដោយហេតុថា ចំណុចនេះអាចមានផលប៉ះពាល់ដល់ធម្មានុរូបភាព និងប្រសិទ្ធភាពរបស់សាលាក្តី។ យុត្តាធិការបុគ្គលដែលត្រូវបានកំណត់មិនរាប់បញ្ចូលបុគ្គល ឬក្រុមសំខាន់ៗដែលនៅក្រៅដែនវិសាលភាពរបស់សាលាក្តីទេ[៧៣]។ ការចោទប្រកាន់មកលើ **ឌុច**[៧៤] ដោយមិនពិចារណាទៅលើបទដ្ឋាននៃច្បាប់ជាតិ[៧៥] ឬក៏ការយល់ដឹងមិនស៊ីជម្រៅអំពីច្បាប់ជាតិ ដែលជាមូលដ្ឋានសម្រាប់ដោះបន្ទុកទាក់ទង

---

[៧១] ១-តុលាការកំពូលប្រទេសកាណាដា ក្នុងសំណុំរឿង R v Finta, [1994] 1.S.C.R.701 Her Majesty the queen V Imire Finta ត្រូវបានចោទប្រកាន់ក្នុងបទឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងពេល Nazi គ្រប់គ្រងអឺរ៉ុបក្នុងសម័យសង្គ្រាមលោកលើកទី២, Case Nos. 23023, 23097. 1993, June, 2,3; 1994, March 24 ។

២-មាត្រា៣៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ស្តីអំពីការជំនុំជម្រះលើអញ្ញត្រកម្ម " តុលាការត្រូវសំរេចអំពីអញ្ញត្រកម្មតាមសាលក្រមមួយដាច់ដោយឡែកអំពីសាលក្រមនៃអង្គសេចក្តី ។ ប៉ុន្តែតុលាការក៏អាចបញ្ចូលឧប្បត្តិហេតុទៅនឹងអង្គសេចក្តី ហើយសំរេចតាមសាលក្រមតែមួយដូចគ្នា អំពីអញ្ញត្រកម្មជាមួយនឹងអង្គសេចក្តី ។

[៧២] មាត្រា២ ថ្មី នៃច្បាប់ អ.វ.ត.ក។

[៧៣] មាត្រា៣ ថ្មី ដល់ មាត្រា ៨ នៃច្បាប់ អវតក តម្រូវឱ្យអង្គជំនុំជម្រះធ្វើការវិនិច្ឆ័យក្តីតែទៅលើ *ជនសង្ស័យ* ប៉ុណ្ណោះ។

[៧៤] កថាខណ្ឌ ១៨ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ វិច្ឆិកា ឆ្នាំ២០១០, (ឯកសារ F14/4 )។

[៧៥] កថាខណ្ឌ២ នៃឧបសម្ព័ន្ធ៥ កិច្ចព្រមព្រៀងទីក្រុងប៉ារីសបានចែងថា ... "*វិធានច្បាប់អន្តរជាតិហាមឃាត់នូវការអនុវត្តន៍ច្បាប់ឧក្រិដ្ឋទៅលើឧក្រិដ្ឋកម្ម ដែលកើតឡើងក្នុងអតីតកាល*"។ មាត្រា៥ នៃច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឱ្យនៅក្រៅច្បាប់ឆ្នាំ១៩៩៤ ចែងថា "*ច្បាប់នេះ អនុគ្រោះទុកពេល ៦ ខែ ក្រោយពីចូលជាធរមាន ឱ្យជនជាសមាជិកអង្គការនយោបាយ ឬជាកម្លាំង*

00635373



F14/4/2

យុត្តាធិការរូបបុគ្គល គឺជាកំហុសឆ្គងរបស់សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះសាលាដំបូង នៃ អវតក ក្នុងការអនុវត្តវិធានផ្ទៃក្នុង[៧៦] របស់ អ.វ.ត.ក ។ អំពើអសមត្ថភាពនេះអាចធ្វើឲ្យប៉ះពាល់ដល់ដំណើរការរួមវិភាគទានរបស់សាលាក្តី ចំពោះការបង្រួបបង្រួមផ្សះផ្សាជាតិ។

៤០. ចម្លើតបទៅនឹងកថាខណ្ឌទី១៩ របស់សហព្រះរាជអាជ្ញា[៧៧] ។ សហព្រះរាជអាជ្ញានៅតែមិនយល់ថា រាល់ការលើកឡើងនៅគ្រប់ទឡ្ហីករណ៍ទាំងអស់ដែលពឹងផ្អែកលើភស្តុតាងក្នុងអង្គហេតុមកគាំទ្រ[៧៨]។ ត្រូវបានគាំទ្រដោយវិធាន ៨៧ នៃវិធានផ្ទៃក្នុង ហើយវិធាន ៨៩ មិនអាចរារាំង វិធាន៨៧បានទេ ដើម្បីអោយវិធាន ៨៧ បើកផ្លូវអោយចៅក្រមនូវមូលដ្ឋានសំរាប់វិនិច្ឆ័យសេចក្តី[៧៩] ។ ការពោលពាក្យថាសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារជនជាប់ចោទ ថាជាអញ្ញត្រកម្មលើកឡើងយឺតពេលរបស់អង្គជំនុំជម្រះគឺសំអាងលើវិធាន៨៩ និយាយអំពីអញ្ញត្រកម្ម ។ ឯសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារជនជាប់ចោទទៅលើយុត្តាធិការបុគ្គលគឺមិនមែនជាអញ្ញត្រកម្មទេ ដូចដែលគ្រប់តុលាការផ្សេងៗទៀតធ្លាប់ពិនិត្យមើល និងយល់ឃើញថាជារឿងត្រឹមត្រូវ[៨០] ។

---

*យោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យ វិលត្រឡប់មករួមរស់ក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ក្នុងព្រះរាជាណាចក្រកម្ពុជាដោយមិនយកទោសពៃរ៍ចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត*" ។

[៧៦] វិធាន៥៣(៤) នៃវិធានផ្ទៃក្នុង អ.វ.ត.ក។

[៧៧] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ វិច្ឆិកា ឆ្នាំ២០១០, កថាខណ្ឌទី១៩ ដែលបានលើកឡើងអំពីអញ្ញត្រកម្ម, (ឯកសារ F14/4 )។

[៧៨] សំណុំរឿងលេខ០០១/១៨ កក្កដា ២០០៧/អវតក/អជសជ ។

[៧៩] វិធាន ៨៧ (១), វិធាន ៨៧(២) អនុញ្ញាតអោយបង្ហាញភស្តុតាងបានគ្រប់ពេលវេលាទាំងអស់នៅក្នុងអង្គជំនុំជម្រះដោយឥតមានប្រើពាក្យថា យឺតពេលទេ ។

[៨០] អនុសាសន៍របស់តុលាការកំពូលកាណាដា ក្នុងរឿង R v Finta, [1994] 1.S.C.R.701 Her Majesty the queen V Imire Finta , Case Nos. 23023, 23097. 1993, June, 2,3; 1994, March 24, "តុលាការកំពូលប្រទេសកាណាបានលើកឡើងថាលក្ខខណ្ឌយុត្តាធិការមិនចាំបាច់បង្ហាញថាហួសពីវិមតិសង្ស័យទេ។ ប៉ុន្តែចៅក្រមជំនុំជម្រះត្រូវតែពិចារណាពីភស្តុតាងដើម្បីបំពេញតាមយុត្តាធិការ ហើយចៅក្រមជំនុំជម្រះមិនគ្រាន់តែផ្អែកតែទៅលើការវាយតម្លៃរបស់ខ្លួនចំពោះលក្ខខណ្ឌទាំងនេះតែទៅលើបទចោទ ដែលគេបានធ្វើឡើងនោះឡើយ ។ ដោយសារតែអង្គហេតុមួយចំនួនដែលចាំបាច់ក្នុងការបង្កើតយុត្តាធិការមិនដូចគ្នានឹងអង្គហេតុដែលចាំបាច់

៤១. ឆ្លើយតបទៅនឹងកថាខណ្ឌ៤៤ របស់សហព្រះរាជអាជ្ញា[៨១] ។ សហព្រះរាជអាជ្ញាបានឆ្លើយសារភាពដោយម៉ឺងម៉ាត់ច្បាស់លាស់ថា **ការកាត់ក្តីគឺតាមការជ្រើសរើស**[៨២] ។ លើសពីនេះទៅទៀតភស្តុតាងដែលបានមកពីការជ្រើសរើសប្រវត្តិរូបរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា[៨៣] ដែលបានដាក់អោយក្រុមអ្នកជំនាញការរបស់អង្គការសហប្រជាជាតិគឺកាន់តែបញ្ជាក់ថា ការកាត់ក្តីនេះគឺជាការកាត់ក្តីតាមការជ្រើសរើសប្រវត្តិរូបដោយឥតប្រកែកបាន ហើយការចោទប្រកាន់របស់សហព្រះរាជអាជ្ញាថា ជនជាប់ចោទគឺជាក្រុមមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យគឺជាការចោទប្រកាន់គ្មានភស្តុតាង និងបង្ហាញពីជំហររំលោភសិទ្ធិអំណាចរបស់សហព្រះរាជអាជ្ញាចំពោះច្បាប់[៨៤] និងជាការសងសឹកមនោគមន៍វិជ្ជានយោបាយសុទ្ធសាធ ។

---

សម្រាប់គណៈវិនិច្ឆ័យ សម្រាប់ការសម្រេចរបស់គណៈវិនិច្ឆ័យលើបទល្មើសដែលកំពុងកើតឡើងនោះ រាល់សេចក្តីសម្រេចមិនអាចធ្វើឡើងដោយគណៈវិនិច្ឆ័យបានទេ ។ ដូចដែលចៅក្រមជំនុំជម្រះពិនិត្យមើលភស្តុតាងទាក់ទងទៅនឹងបញ្ហាយុត្តាធិការដែរនោះជាទូទៅវានឹងមានប្រសិទ្ធិភាពជាង ប្រសិនបើឲ្យចៅក្រមជំនុំជម្រះគិតពិចារណាពីបញ្ហាយុត្តាធិការស្របគ្នានឹងពេលដែលគណៈវិនិច្ឆ័យពិនិត្យមើលភស្តុតាងដែលទាក់ទងនឹងបទល្មើសដែរ ។ ទាំងអស់នេះជាការបង្ហាញឲ្យឃើញថា ភស្តុតាងដែលចង្អុលបង្ហាញយុត្តាធិការរបស់សាលាជម្រះក្តីនៅតែមានសារប្រយោជន៍ និងត្រូវបានគេលើកយកមកបង្ហាញ និងទាញជាអំណះអំណាងបានគ្រប់ពេលវេលាដោយពឹងផ្អែកទៅលើសក្ខីកម្មផ្តល់ដោយអ្នកជំនាញការ ឬសាក្សីដ៏មានសក្តានុពលនានា ។ ការទាត់ចោលភស្តុតាងចង្អុលបង្ហាញពីបញ្ហាយុត្តាធិការសាលាជម្រះក្តី ដោយការលើកឡើងថាមិនបានឡើកឡើងទាន់ពេលវេលា មិនអាចទទួលយកបានតាមបណ្តាប្រព័ន្ធតុលាការនៅអរិយប្រទេសមួយចំនួន" ។

[៨១] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ វិច្ឆិកា ឆ្នាំ២០១០ , កថាខណ្ឌទី៤៤ ទំព័រទី៣៩, (ឯកសារ F14/4 ) ។

[៨២] នៅក្នុងកថាខណ្ឌ៤៤ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ វិច្ឆិកា ឆ្នាំ២០១០ (ឯកសារ F14/4 ) , សហព្រះរាជអាជ្ញាបានសារភាពដោយម៉ឺងម៉ាត់ថា កិច្ចព្រមព្រៀងបង្កើត អវតក និងច្បាប់ អវតក គ្មានតំរូវកាតព្វកិច្ចណាមួយអោយត្រូវតែធ្វើការជំនុំជម្រះក្តីលើរាល់ចារី ដែលមានសក្តានុពលគ្រប់ទាំងអស់នៃឧក្រិដ្ឋកម្មដែលស្ថិតក្នុងរង្វង់ដែនសមត្ថកិច្ចខ្លួននោះទេ ។

[៨៣] The selected 31 Biographies of Khmer Rough Leaders and others, Prepared for The UN Commision of Experts August-September, 1998 (Duch's Biography) , ERN 00626210-00626212, (ឯកសារ F14.2.4 ) ។

[៨៤] រំលោភមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងបង្កើត អវតក ។ រំលោភមាត្រា១ មាត្រា២(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អវតក ។ រំលោភលើវិធាន ៨៧(១), ៨៧(២) វិធានស្តីពីភស្តុតាងនៃវិធានផ្ទៃក្នុង អវតក ។

00635375



F14/4/2

៤២. សហព្រះរាជអាជ្ញាមិនបានពឹងផ្អែកលើភស្តុតាងដាក់ដោយអ្នកជំនាញការ Craig C. Etcheson នៅការិយាល័យសហព្រះរាជអាជ្ញាខ្លួនឯង[៨៥] ។ គ្មានទស្សីករណ៍ គ្មានអត្ថបទច្បាប់ពោលអះអាង ។ រាល់សំណេរឆ្លើយតបរបស់សហព្រះរាជអាជ្ញា ពឹងផ្អែកលើការណែនាំរបស់សាលាក្តីផ្សេងទៀតច្រើនជ្រុល វាហាក់បីដូចជាមិនឆ្លុះបញ្ចាំងពីអំណាចពិតដែលច្បាប់ផ្តល់អោយ និងមានការឃ្លាតឆ្ងាយពីការអប់រំនៅឯសាលាច្បាប់នានាជុំវិញពិភពលោក ។

៤៣. ឆ្លើយតបទៅនឹងកថាខណ្ឌ៤៥ នៃចម្លើយតបរបស់សហព្រះរាជអាជ្ញា[៨៦] ។ សហព្រះរាជអាជ្ញានៅមានបញ្ហាការអប់រំច្បាប់ ។ ពាក្យថាសមភាពចំពោះមុខច្បាប់តាមមាត្រា៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា បានត្រូវលើកឡើងយ៉ាងល្អឥតខ្ចោះ ដោយសហមេធាវីការពារជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ។ សហព្រះរាជអាជ្ញាខ្លួនឯងបកស្រាយថាគឺយោងទៅដល់សញ្ញាណជាទូទៅ ដែលថាជនទូទៅត្រូវស្ថិតនៅក្រោមច្បាប់ដូចគ្នាដោយឥតគិតពីពូជសាសន៍ ធនធាន ភេទ ឬឋានៈសង្គម បក្សពួកអ្វីឡើយ ។ ហេតុនេះបើគេប្រព្រឹត្តខុសអ្វីមួយជាបទល្មើសដូចគ្នានោះគេត្រូវតែយកមកកាត់ទោសដូចគ្នាដោយឥតលើកលែងទេ ។ ហេតុដូច្នេះបើប្រធានមន្ទីរឃុំឃាំងផ្សេងៗទៀតទាំង១៩៥[៨៧] នៅទូទាំងប្រទេសកម្ពុជា បានប្រព្រឹត្តដូចគ្នាដែលជាបទល្មើសស្ថិតនៅក្នុងយុត្តាធិការជម្រះក្តី អវតក នោះសហព្រះរាជអាជ្ញាគ្មានសិទ្ធិអ្វីនឹងគេចវេសមិនចោទប្រកាន់តាមការពោលអះអាងថា **គ្មានច្បាប់ឯណាបង្គាប់អោយសហព្រះរាជអាជ្ញាធ្វើយ៉ាងដូចនេះ** ។ ជាការពិតមាត្រា១ នៃកិច្ចព្រមព្រៀងបង្កើត អវតក និងមាត្រា១ មាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក ជាអ្នកចងកាតព្វកិច្ចដល់អ្នករាល់រូបរួមទាំងសហព្រះរាជអាជ្ញា អវតក ផងថាដាច់ខាតត្រូវតែគោរពតាម ដោយខានមិនបាន ។ ជាពិសេសមន្ទីរសន្តិសុខចុងជ្រោយ[៨៨] ។ មានមនុស្សស្លាប់

---

[៨៥] របាយការណ៍អ្នកជំនាញការ Craig C. Etcheson , (ឯកសារ E3/32 )។

[៨៦] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០ ,កថាខណ្ឌទី៤៥ ទំព័រ៤១, (ឯកសារ F14/4 ) ។

[៨៧] គុកខ្មែរក្រហម ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា (DK PRISON) សំណុំរឿងលេខ០០១/១៨ -០៧-២០០៧/អវតក/អជសង (ឯកសារ E3/220 ) ។

[៨៨] គុកខ្មែរក្រហម ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា ចងក្រងដោយ ឆេង ពង្សរ៉ាស៊ី ,ទំព័រ ៨១ (ភាសាខ្មែរ) ។

ច្រើនជាងដប់ដងនៃស-២១ ហើយប្រធានសន្តិសុខចុងជ្រោយក៏ជាលេខាមន្ទីរសន្តិសុខចុងជ្រោយដែរ[៨៩] ។ វាស្របគ្នាណាស់ទៅនឹងសេចក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦[៩០] ដែលអនុញ្ញាតអោយស-២១ ទទួលបញ្ជាពីគ្រប់អង្គភាពយោធាមជ្ឈិមបក្ស ដើម្បីកំទេចមនុស្សជុំវិញមជ្ឈិម ឯមន្ទីរសន្តិសុខភូមិភាគត្រូវទទួលបញ្ជាពីភូមិភាគ ។ ហេតុនេះបើចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ថាជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មនោះ ក៏ត្រូវចោទប្រកាន់ប្រធានមន្ទីរសន្តិសុខផ្សេងទៀតបានដែរ ដោយទទ្បីករណ៍ដូចគ្នាអំពីយុត្តាធិការបទល្មើស ។ **ក៏ប៉ុន្តែបើសិនជាដូចការយល់ស្របរបស់សហព្រះរាជអាជ្ញាថា គ្មានយុត្តាធិការលើបុគ្គលជាប្រធានមន្ទីរសន្តិសុខនានាទូទាំងប្រទេសទាំង១៩៥ នោះ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ជាប្រធាន ស-២១ ក៏ដូចគ្នាដែរ ។**

## III. ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាក្នុងទទ្បីករណ៍ទី២[៩១]

៤៤. សហព្រះរាជអាជ្ញាខកខានមិនបានបង្ហាញទទ្បីករណ៍ណាមួយថាមិនមានការភាន់ច្រឡំលើយុត្តាធិការទាល់តែសោះ ហើយនិយាយច្រំដែលៗដូចមានក្នុងសំណុំរឿងលេខ០០១/១៨-០៧-២០០៧/អវតក/អជសង តែអំពីការជឹងឮលើរបៀបកាត់ក្តីនៅ ICTY [៩២] ។

៤៥. ដូចនៅ ICTY ដែរ រដ្ឋអាជ្ញាក៏ធ្លាប់បានតវ៉ាថា អង្គជំនុំជម្រះខកខានមិនបានបង្ហាញភស្តុតាងដែលគ្មានវិមតិសង្ស័យឲ្យបានត្រឹមត្រូវតាមស្តង់ដារដើម្បីវិនិច្ឆ័យ[៩៣]។ វាដូចគ្នាណាស់នៅទីនេះ ដែលសហ-

---

[៨៩] គុកខ្មែរក្រហម ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា ចងក្រងដោយ ផេង ពង្សរ៉ាស៊ី ,ទំព័រ ៨១ (ភាសាខ្មែរ) ។

[៩០] សេចក្តីសម្រេចរបស់គណៈមជ្ឈិមអំពីបញ្ហាផ្សេងៗមួយចំនួនចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦, ERN 00003136-00003142 ។

[៩១] ចម្លើយតបទៅនឹងទទ្បីករណ៍ទី២៖ អង្គជំនុំជម្រះមិនមានការភាន់ច្រឡំ "ចំពោះការផ្តន្ទាទោស" ទំព័រ៤៣ ។

[៩២] អង្គជំនុំជម្រះមិនបានបង្ហាញភស្តុតាងដែលត្រូវទាញចេញពីអង្គហេតុដែលកើតឡើងក្នុងអំឡុងពេលពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ នៅក្នុងទឹកដីកម្ពុជា ក្នុងគុកទួលស្លែង (ស-២១) និងមានកង្វះខាតការទាញបង្ហាញ អត្ថបទច្បាប់ជាតិ និងអន្តរជាតិដែលមានសុពលភាពឲ្យអស់លទ្ធភាព។

មេធាវីទាមទារឲ្យអង្គជំនុំជម្រះត្រួតពិនិត្យភស្តុតាងទាំងអស់ ដែលដាក់ដោយការិយាល័យសហព្រះរាជអាជ្ញា[៥៤] និងភាគីផ្សេងទៀតក្នុងការត្រួតពិនិត្យភស្តុតាងអំពីយុត្តាធិការរបស់ខ្លួន ។

៤៦. នៅក្នុងអង្គជំនុំជម្រះ អជសដ នៃ អវតក មិនបានត្រួតពិនិត្យភស្តុតាងទាំងអស់អោយស្របតាមស្តង់ដារដែលគួរអោយជឿបានដោយឥតទុកអោយមានវិមតិសង្ស័យឡើយ អំពីការពោលអះអាងថា ខ្លួនមានយុត្តាធិការបុគ្គលទៅលើរូបជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ដែលនឹងត្រូវចងភ្ជាប់ទៅនឹងមាត្រា១ មាត្រា២ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក និងគោលបំណងនៃការបង្កើត អវតក តាមមាត្រា១ នៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា ។ ដូចដែលនៅឯ ICTY រដ្ឋអាជ្ញាបានតវ៉ាថា អង្គជំនុំជម្រះត្រូវតែត្រួតពិនិត្យភស្តុតាងអោយអស់ការសង្ស័យ (Beyond reasonable doubt standard) ដើម្បីពិនិត្យមើលអត្ថិភាពនៃយុត្តាធិការរបស់ខ្លួន[៥៥] ។ ថ្វីបើពេលនោះរដ្ឋអាជ្ញាតវ៉ាដើម្បីអោយអង្គជំនុំជម្រះចោទប្រកាន់ជនជាប់ចោទថាស្ថិតនៅក្នុងយុត្តាធិការរបស់ខ្លួនក៏ដោយ ក៏វាមានន័យថាអង្គជំនុំជម្រះ ICTY ក៏ដូចជាតុលាការកំពូលប្រទេសកាណាដាផងដែរ សុទ្ធតែធ្លាប់បានជជែកគ្នា និងបានយល់ស្របថាអង្គជំនុំជម្រះគ្រប់ពេលត្រូវពិនិត្យមើលលើភស្តុតាងដោយប្រព្រឹត្តតាមស្តង់ដារដែលត្រូវធ្វើអោយប្រាកដថា គ្មានវិមតិសង្ស័យ ទាំងភស្តុតាងលើយុត្តាធិការបទល្មើស និងភស្តុតាងយុត្តាធិការលើរូបបុគ្គល[៥៦] ។ ហេតុដូច្នេះ

---

[៥៣] សូមអាន Appeals Chamber the Hague, 16 November 2005 JP/MO/1021e. Summary of the appeals judgment ករណី Prosecutor v. Sefer Halilović ទំព័រទី៣ កថាខណ្ឌទី១ ។ ICTY, http://www.icty.org/x/cases/halilovic/tjug/en/051116_halilovic_summary_en.pdf. http://www.icty.org/x/cases/halilovic/acjug/en/071016_Halilovic_summary_en.pdf

[៥៤] សូមអាន Appeals Chamber the Hague, 16 November 2005 JP/MO/1021e. Summary of the appeals judgment ករណី Prosecutor v. Sefer Halilović ទំព័រទី៣ កថាខណ្ឌទី២ ។ ICTY, http://www.icty.org/x/cases/halilovic/tjug/en/ 051116 halilovic summary en.pdf. http://www.icty.org/x/cases/halilovic/acjug/en/071016_Halilovic_summary_en.pdf

[៥៥] សូមអាន Appeals Chamber the Hague, 16 November 2005 JP/MO/1021e. Summary of the appeals judgment ករណី Prosecutor v. Sefer Halilović ទំព័រទី៣ កថាខណ្ឌទី២ ។ ICTY, http://www.icty.org/x/cases/halilovic/tjug/en/ 051116_halilovic_summary_en.pdf.http://www.icty.org/x/cases/halilovic/acjug/en/071016_Halilovic_summary_en.pdf ។

[៥៦] អនុសាសន៍របស់តុលាការកំពូលកាណាដា ក្នុងរឿង R v Finta, [1994] 1.S.C.R.701 Her Majesty the queen V Imire Finta, Case Nos. 23023, 23097. 1993, June, 2,3; 1994, March 24, "តុលាការកំពូលប្រទេសកាណាដាបានលើកឡើងថាលក្ខខណ្ឌ

ប្រសិនបើចៅក្រមបានពិនិត្យភស្តុតាងយ៉ាងត្រឹមត្រូវ អំពីយុត្តាធិការបុគ្គលដូចគ្នានឹងការលើកឡើងខាងលើ ហើយ ឃើញថា **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ជាបុគ្គលដែលមានឋានៈទាបជាងគេក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា[៩៧] នោះអង្គជំនុំជម្រះត្រូវចេញសាលក្រមថាគ្មានសមត្ថកិច្ច មិនមែនចេញសាលក្រមផ្តន្ទាទោសដាក់

---

យុត្តាធិការមិនចាំបាច់បង្ហាញថាហួសពីវិមតិសង្ស័យទេ។ ប៉ុន្តែចៅក្រមជំនុំជម្រះត្រូវតែពិចារណាពីភស្តុតាងដើម្បីបំពេញតាមយុត្តាធិការ ហើយចៅក្រមជំនុំជម្រះមិនគ្រាន់តែផ្អែកតែទៅលើការវាយតម្លៃរបស់ខ្លួនចំពោះលក្ខខណ្ឌទាំងនេះតែទៅលើបទចោទ ដែលគេបានធ្វើឡើងនោះឡើយ ។ ដោយសារតែអង្គហេតុមួយចំនួនដែលចាំបាច់ក្នុងការបង្កើតយុត្តាធិការមិនដូចគ្នានឹងអង្គហេតុដែលចាំបាច់សម្រាប់គណៈវិនិច្ឆ័យ សម្រាប់ការសម្រេចរបស់គណៈវិនិច្ឆ័យលើបទល្មើសដែលកំពុងកើតឡើងនោះ រាល់សេចក្តីសម្រេចមិនអាចធ្វើឡើងដោយគណៈវិនិច្ឆ័យបានទេ ។ ដូចដែលចៅក្រមជំនុំជម្រះពិនិត្យមើលភស្តុតាងទាក់ទងទៅនឹងបញ្ហាយុត្តាធិការដែរនោះ ជាទូទៅវានឹងមានប្រសិទ្ធិភាពជាង ប្រសិនបើឱ្យចៅក្រមជំនុំជម្រះគិតពិចារណាពីបញ្ហាយុត្តាធិការស្របគ្នានឹងពេលដែលគណៈវិនិច្ឆ័យពិនិត្យមើលភស្តុតាងដែលទាក់ទងនឹងបទល្មើសដែរ ។ ទាំងអស់នេះជាការបង្ហាញឱ្យឃើញថា ភស្តុតាងដែលចង្អុលបង្ហាញយុត្តាធិការរបស់សាលាជម្រះក្តីនៅតែមានសារប្រយោជន៍ និងត្រូវបានគេលើកយកមកបង្ហាញ និងទាញជាអំណះអំណាងបានគ្រប់ពេលវេលាដោយពឹងផ្អែកទៅលើសក្ខីកម្មផ្តល់ដោយអ្នកជំនាញការ ឬសាក្សីដ៏មានសក្តានុពលនានា ។ ការទាត់ចោលភស្តុតាងចង្អុលបង្ហាញពីបញ្ហាយុត្តាធិការសាលាជម្រះក្តី ដោយការលើកឡើងថាមិនបានឡើកឡើងទាន់ពេលវេលា មិនអាចទទួលយកបានតាមបណ្តាប្រព័ន្ធតុលាការនៅអរិយប្រទេសមួយចំនួន" ។

[៩៧] របាយការណ៍របស់អ្នកជំនាញការ Craig C. Etcheson, E3/32 និង អនុសាសន៍របស់តុលាការកំពូលកាណាដា ក្នុងរឿង R v Finta, [1994] 1.S.C.R.701 Her Majesty the queen V Imire Finta , Case Nos. 23023, 23097. 1993, June, 2,3; 1994, March 24, "តុលាការកំពូលប្រទេសកាណាបានលើកឡើងថាលក្ខខណ្ឌយុត្តាធិការមិនចាំបាច់បង្ហាញថាហួសពីវិមតិសង្ស័យទេ។ ប៉ុន្តែចៅក្រមជំនុំជម្រះត្រូវតែពិចារណាពីភស្តុតាងដើម្បីបំពេញតាមយុត្តាធិការ ហើយចៅក្រមជំនុំជម្រះមិនគ្រាន់តែផ្អែកតែទៅលើការវាយតម្លៃរបស់ខ្លួនចំពោះលក្ខខណ្ឌទាំងនេះតែទៅលើបទចោទ ដែលគេបានធ្វើឡើងនោះឡើយ។ ដោយសារតែអង្គហេតុមួយចំនួនដែលចាំបាច់ក្នុងការបង្កើតយុត្តាធិការមិនដូចគ្នានឹងអង្គហេតុដែលចាំបាច់សម្រាប់គណៈវិនិច្ឆ័យ សម្រាប់ការសម្រេចរបស់គណៈវិនិច្ឆ័យលើបទល្មើសដែលកំពុងកើតឡើងនោះ រាល់សេចក្តីសម្រេចមិនអាចធ្វើឡើងដោយគណៈវិនិច្ឆ័យបានទេ ។ ដូចដែលចៅក្រមជំនុំជម្រះពិនិត្យមើលភស្តុតាងទាក់ទងទៅនឹងបញ្ហាយុត្តាធិការដែរនោះ ជាទូទៅវានឹងមានប្រសិទ្ធិភាពជាង ប្រសិនបើឱ្យចៅក្រមជំនុំជម្រះគិតពិចារណាពីបញ្ហាយុត្តាធិការស្របគ្នានឹងពេលដែលគណៈវិនិច្ឆ័យពិនិត្យមើលភស្តុតាងដែលទាក់ទងនឹងបទល្មើសដែរ ។ ទាំងអស់នេះជាការបង្ហាញឱ្យឃើញថា ភស្តុតាងដែលចង្អុលបង្ហាញយុត្តាធិការរបស់សាលាជម្រះក្តីនៅតែមានសារប្រយោជន៍ និងត្រូវបានគេលើកយកមកបង្ហាញ និងទាញជាអំណះអំណាងបានគ្រប់ពេលវេលាដោយពឹងផ្អែកទៅលើសក្ខីកម្មផ្តល់ដោយអ្នកជំនាញការ ឬសាក្សីដ៏មានសក្តានុពលនានា ។ ការទាត់ចោលភស្តុតាងចង្អុលបង្ហាញពីបញ្ហាយុត្តាធិការសាលាជម្រះក្តី ដោយការលើកឡើងថាមិនបានឡើកឡើងទាន់ពេលវេលា មិនអាចទទួលយកបានតាមបណ្តាប្រព័ន្ធតុលាការនៅអរិយប្រទេសមួយចំនួន"។

ពន្ធនាគារសរុប ៣៥ឆ្នាំ[៩៨] នោះទេ។ ហេតុដូច្នេះយើងឃើញថា សាលាដម្រះក្តីយ៉ាងតិចពីរដែលបានយល់ស្របតាមសេចក្តីសន្និដ្ឋានរបស់សហមេធាវីការពារជនជាប់ចោទ ។

៩៧. ទឡ្ហីករណ៍ទី១ និងទី២ ត្រូវតែមានលក្ខណៈពាក់ព័ន្ធគ្នា ត្បិតអីទឡ្ហីករណ៍ទី១ បានបង្ហាញពីភស្តុតាងទាញចេញពីអង្គហេតុកើតឡើងនៅគុកទួលស្លែង ចន្លោះពីថ្ងៃទី១៧ មេសា ១៩៧៥ ដល់ថ្ងៃទី០៦ មករា ១៩៧៩ ឯទឡ្ហីករណ៍ទី២ បានទាញបង្ហាញពីអត្ថបទច្បាប់ជាតិ ច្បាប់អន្តរជាតិ និងប្រភពច្បាប់អន្តរជាតិយ៉ាងត្រឹមត្រូវ។មិនដូចគ្នាទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញា[៩៩] ដែលគ្មានភស្តុតាងដែលគ្មានវិមតិសង្ស័យណាមួយលើកមកបង្ហាញ បើទោះបីជាការិយាល័យរបស់ខ្លួនបានដាក់ភស្តុតាងយ៉ាងច្រើនរួមទាំងសេចក្តីសន្និដ្ឋានរបស់អ្នកជំនាញការប្រចាំការិយាល័យរបស់ខ្លួនផង[១០០]។

## IV. សេចក្តីសន្និដ្ឋាន

៩៨. សហព្រះរាជអាជ្ញា ឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ដោយប្រើប្រាស់ស្តង់ដារទ្វេ និងរំលោភអំណាច ។

-មិនពិនិត្យស៊ើបអង្កេតលើចម្លើយផ្តល់ដល់សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត នូវបញ្ហាជនទាំងឡាយណាដែលមានឋានៈខ្ពស់ជាងជនជាប់ចោទ និងសហចារី ឬសហសេវិក ដូចជនជាប់ចោទដែរ ។ ពេលឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ សហព្រះរាជអាជ្ញានិយាយយ៉ាងទូទៅដោយឥតមានភស្តុតាងជំទាស់ និងលើកអត្ថបទច្បាប់មកបង្ហាញ ។

[៩៨] សាលក្រមចុះថ្ងៃទី២៦ កក្កដា ឆ្នាំ២០១០, កថាខណ្ឌ៦៧៩, (ឯកសារ E188 ) ។

[៩៩] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០ , (ឯកសារ F14/4 ) ។

[១០០] របាយការណ៍របស់អ្នកជំនាញការ Craig C. Etcheson, (ឯកសារ E3/32 )។

-សហព្រះរាជអាជ្ញាលើកឡើងថា គ្មានច្បាប់ណាបង្គាប់ឱ្យសហព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ទៅលើចារីដែលដល់ ។ តាមពិត មាត្រា១ នៃកិច្ចព្រមព្រៀងនិយាយច្បាស់ពីសិទ្ធិអំណាចរបស់សហព្រះរាជអាជ្ញាដែលមានយុត្តាធិការលើឋានៈបុគ្គលយ៉ាងច្បាស់ គឺមានតែពីរក្រុមទេ៖ **គឺក្រុមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ** និង **ក្រុមអ្នកទទួលខុសត្រូវខ្ពស់បំផុត** នៃឧក្រិដ្ឋកម្ម ។ បើសិនជាគេរកមិនឃើញនូវធាតុផ្សំទាំងឡាយណា ដែលកំណត់ឋានៈបុគ្គលនៃក្រុមទាំងពីរនេះបាននោះ សហព្រះរាជអាជ្ញាគ្មានសិទ្ធិចោទប្រកាន់ទេ គឺវាស្ថិតនៅក្រៅរង្វង់អំណាចរបស់សហព្រះរាជអាជ្ញា អវតក យ៉ាងពិតប្រាកដ។ ច្បាស់ណាស់ថាសហព្រះរាជអាជ្ញាសារភាពថា គ្មានច្បាប់ឯណាបង្គាប់អោយសហព្រះរាជអាជ្ញាចោទប្រកាន់ទៅលើចារី គឺជារឿងពិត ហើយ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** ក៏ដូចសហសេវិកគាត់ដែរគឺជាក្រុមចារីនៃ ស-២១ ឯ **សុន សេន** , **នួន ជា** និង **ប៉ុល ពត** គឺជាអ្នករៀបចំ និងដាក់បទឧក្រិដ្ឋនេះអោយដំណើរការបានដល់ចប់ ឬបញ្ឈប់វាបាន ត្បិតក្រុមនេះគឺជាជនដែលទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្មនៅ ស-២១ ។

-អ្នកទទួលខុសត្រូវនៃមន្ទីរឃុំឃាំងទាំង១៩៥[១០១] នៅទូទាំងប្រទេសមិនត្រូវបានគេធ្វើការចោទប្រកាន់ គឺជាការត្រឹមត្រូវស្របតាមមាត្រា ១ នៃកិច្ចព្រមព្រៀងរវាង អសប និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា១, មាត្រា២ថ្មី នៃច្បាប់ស្ដីពីការបង្កើត អវតក ឯ **កាំង ហ្កេកអ៊ាវ** ហៅ **"ឌុច"** ក៏ដូចគ្នាដែរ ។

៤៩. សហព្រះរាជអាជ្ញា ខកខានមិនបានឆ្លើយតបដោយភ្ជាប់មកនូវភស្តុតាងទាញចេញពីអង្គហេតុ និងអត្ថបទច្បាប់ ឬប្រភពច្បាប់អន្តរជាតិជាក់លាក់ណាមួយមកកំណត់តំលៃនៃការឆ្លើយតបរបស់ខ្លួនទេ ក្រៅតែពីប្រើករណីយុត្តិសាស្ត្រនៃសាលាក្ដី ICTY ។

---

[១០១] គុកខ្មែរក្រហម ឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជា (DK PRISON) សំណុំរឿងលេខ០០១/១៨ -០៧-២០០៧/អវតក/អជសង (ឯកសារ E3/220 )។

៥០. ការប្រើប្រាស់ករណីយុត្តិសាស្ត្រមិនត្រឹមត្រូវតាមស្តង់ដារក៏ធ្លាប់ត្រូវបានអង្គជំនុំជម្រះ ICTY ច្រានចោលផងដែរ[១០២] ។ ហេតុដូចនេះ អង្គជំនុំជម្រះតុលាការកំពូលត្រូវតែលើកយកបណ្តឹងសាទុក្ខរបស់សហមេធាវីការពារក្តីជនជាប់ចោទមកពិនិត្យ លើភស្តុតាងថ្មីៗ និងទឡ្ហីករណ៍ស្របតាមស្តង់ដារព្រមទាំងការចង្អុលបង្ហាញអត្ថបទច្បាប់ច្បាស់លាស់របស់សហមេធាវីការពារក្តីជនជាប់ចោទ ជូនអង្គជំនុំជម្រះតុលាការកំពូលពិនិត្យ ហើយទាំងអស់នេះអង្គជំនុំជម្រះសាលាដំបូង អវតក ខកខានមិនបានលើកឡើង ។

៥១. ការសន្មត់ថាភស្តុតាងទាំងអស់ត្រូវបានពិនិត្យគឺជាស្តង់ដារ ក្រោមស្តង់ដារអប្បរមារបស់តុលាការថ្នាក់ជាតិដែលត្រូវតែទាត់ចោលនូវភស្តុតាងដែលមានវិមតិសង្ស័យ ។ ហេតុដូច្នេះអំណះអំណាងរបស់សហព្រះរាជអាជ្ញា ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ **កាំង ហ្កេកអ៊ាវ** ហៅ **ឌុច** គឺមិនមានទឡ្ហីករណ៍ច្បាស់លាស់ ហើយមិនអាចយកជាការបានទេ ៕

## សូមរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | | |
|---|---|---|---|
| ១៨-០១-២០១១ | សហមេធាវីជាតិ<br>មេធាវី **ការ សាវុត្ថ**<br>មេធាវី **កង រិទ្ធារី** | ភ្នំពេញ | |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |

[១០២] ចម្លើយតបរបស់សហព្រះរាជអាជ្ញាចំពោះសារណាបណ្តឹងសាទុក្ខរបស់សហមេធាវីការពារជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច ចុះថ្ងៃទី២០ ធ្នូ ឆ្នាំ២០១០, កថាខណ្ឌ៥៤ ទំព័រ ៤៨ , (ឯកសារ F14/4 )។